គេហៅតំបន់ក្បែរព្រះចេតិយនេះថាស្សៃណាប៊ីយ៉ាស់ (الزينبية) ។ ជនជាតិស៊ីរីក្នុងស្រុកគោរពនិងលើកតម្កើងព្រះនាងسَلَامُ اللهِ عَلَيْهَا ។ តែគេពុំឃើញមានការនឹកនាដល់យ៉ាស៊្សីដូទេ ពុំឃើញមានសំណង់រំលឹកយ៉ាស៊្សីដូទេ ។

ដូច្នេះ ដើម្បីថ្លែងសាឡើងវិញនិងបញ្ចប់សេចក្តី អ្នកចាញ់គឺយ៉ាស៊្សីដូ ។ អ្នកឈ្នះពិតប្រាកដនៅការបាទ្បាអ៊័គឺហ៊្សសែន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ និងព្រះសាសនាអ៊ីស្លាមព្រះសាសនាដើមពិតឥតក្លែងក្លាយរបស់ព្រះសាស្តាមូហ៊ាំម៉ាដ់صَلَّى اللهُ عَلَيْهِ وَآلِهِ ។

# យល់ដឹងថ្ងៃអាស៊ូរ៉

# អ៊ីម៉ាំហ៊្សសែន៍ صلوات الله عليه والسلام

# ការបាទ្បាអ៊័

ប្រយុទ្ធគ្មានទីបំផុតរបស់ប្រការល្អទល់នឹងប្រការអាក្រក់ ការពិតទល់នឹងអ្វីដែលមិនពិត យុត្តិធម៌ទល់នឹងអយុត្តិធម៌ ដែលព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُជានិមិត្តសញ្ញាសម្រាប់បដិវត្តន៍ទាំងអស់របស់បណ្ដាជនរងការសង្កត់សង្កិន ដែលប្រឆាំងបុគ្គសង្កត់សង្កិនគេ ។

ពុំមានព្រះនាងទាំងពីរផ្សាយពាក្យពេជន៍ច្រើនសប្ដាហ៍ ច្រើនខែបន្ទាប់សោកនាដកម្មថ្ងៃអាស៊ូរ៉ទេ គោលដៅរបស់ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُនឹងបាត់បង់ សាបសូន្យ សោកនាដកម្មការបាឡាអ៊្នឹងត្រូវប្រវត្តិសាស្ត្របំភ្លេចចោល ឬត្រូវកប់ចោលក្រោមគំនរនៃការបង្ខូច និងការបកស្រាយខុសរបស់ពួកអ៊ូម៉ៃយ៉ាស់ - សូមអល់ឡោះហ៊្عَزَّ وَجَلَّជួយថែរក្សាការពារឲ្យបានគង់វង្ស ។

មុស្លីមត្រូវតែយល់ព្រមនិងទទួលស្គាល់ការពិតដ៏សំខាន់នេះ ត្រូវយល់ការពិតនេះ ផ្សាយការពិតនេះឲ្យច្រើន ។ បន្ទាប់ពីនេះទើបយើងអាចធ្វើការវិនិច្ឆ័យបាន អំពីតួនាទីរបស់ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُនិងព្រះនាងស៊ៃណាប់سَلَامُ اللهِ عَلَيْهَا ។

ដោយសារព្រះនាងស៊ៃណាប់سَلَامُ اللهِ عَلَيْهَا បានជាបណ្ដាមុស្លីមគោរពព្រះសន្តអ៊ីម៉ាំហ៊ូសែន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ទាំងមុស្លីមស៊ុន្នី ទាំងមុស្លីមស៊ីអាស់ ហៅព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُថា "ព្រះអង្គម្ចាស់របស់បណ្ដាទុក្ករបុគ្គល" ។ មុស្លីមទាំងអស់ចងចាំយ៉ាស៊ីដបានដោយសារអំពើរបស់យ៉ាស៊ីដគឺ៖ កាចសាហាវ អាក្រក់ សត្រូវផ្ដាច់ការរបស់អ៊ីស្លាម ។

សញ្ញាច្បាស់បំផុតនៃជ័យជំនះរបស់ព្រះនាងسَلَامُ اللهِ عَلَيْهَاគឺ បើអស់លោកអ្នកទៅកាន់ស្រុកដ្វាម៉ាស់ប្រទេសស៊ីរីសព្វថ្ងៃនេះ អស់លោកអ្នកនឹងបានឃើញរ៉ៅដោះត៍ (الروضة ព្រះចេតិយ) ដ៏ប្រណិតរបស់ព្រះនាងស៊ៃណាប់سَلَامُ اللهِ عَلَيْهَا ។

បានឲ្យបែអាស្ទុ់ទេ ! ប្រវត្តិសាស្ត្របញ្ជាក់ថាព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام ស៊ែន៍ អាល់-អាប៊ីឌ្ទីន صلوات الله عليه والسلام ព្រះសន្តអ៊ីម៉ាំស៊្ទីអាស្ទុ់ទីបួន មិនបានសច្ចាស្មោះស្ម័គ្រយ៉ាស៊ីដ្ទជាដាច់ខាតនៅឯរាជវាំងស្រុកគូហ្វាស្ទុ់ឬស្ហាំ (ប្រទេសស៊ីរី) យ៉ាស៊ីដ្ទក៏ពុំបានសូមឲ្យព្រះអង្គ صلوات الله عليه والسلام សច្ចាស្មោះស្ម័គ្រដែរ ។

ការពិត ក្រោយសមរភូមិការបាឡាអ៊ុំ ពុំមានអ៊ីម៉ាំស៊្ទីអាស្ទុ់ណាមួយត្រូវសូមឲ្យសច្ចាស្មោះស្ម័គ្រដោយអនាគតស្តេចខ៊ិលិហ្វត្រកូលអ៊ូម៉ៃយ៉ាស្ទុ់ ឬអនាគតស្តេចខ៊ិលិហ្វត្រកូលអាប់បាស៊ីយ៉ាស្ទុ់ណាមួយឡើយ ។ ព្រះសន្តអ៊ីម៉ាំសាច់ឌ្យ៉ាដ្ទុំ صلوات الله عليه والسلام បានប្រាប់បុរសដែលបានប្រមាថព្រះអង្គ صلوات الله عليه والسلام ថាអ្វីនៅដ្ទាម៉ាស់ ? ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ចូររង់ចាំអាស្ទាន លោកនឹងបានឃើញអ្នកណាឈ្នះ អ្នកណាចាញ់..."

សព្វថ្ងៃនេះ ដោយសារពលីកម្មរបស់ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام អាស្ទាននៅតែមានព្រះនាមរបស់មូហ៊្ហាំម៉ាដ្ទុំ صلى الله عليه وآله អ៊ីស្លាមនៅតែដូចដើម ។

## តួនាទីរបស់ព្រះនាងស៊ែណាប់និងព្រះនាងអ៊ូម គុលស៊្ហូម

បើពុំមានព្រះនាងស៊ែណាប់ سلام الله عليها និងព្រះនាង អ៊ូម គុលស៊្ហូម سلام الله عليها ទេនោះ ដែលជាព្រះរាជអនុជា (ប្អូនស្រី) ទាំងពីររបស់ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام ជាព្រះរាជនត្តា (ចៅស្រី) របស់ព្រះសាស្តាមូហ៊្ហាំម៉ាដ្ទុំ صلى الله عليه وآله បណ្តាមុស្លីមប្រាកដជាមិនបានដឹង គោលដៅនៃពលីកម្មកំពូលរបស់ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام ទេ ។ មហាស្ត្រីទាំងពីរអង្គនេះបានបង្គ្រប់បេសកកម្មរបស់ព្រះអង្គ صلوات الله عليه والسلام បានផ្សព្វផ្សាយសារព័ត៌មានការបាឡាអ៊ុំ ។

យើងនឹងពុំបានយល់ទេនូវខ្លឹមសារ ដែលព្រះអង្គ صلوات الله عليه والسلام ជាតួអង្គនៃការ

# កថាមុខ

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ

បុគ្គលមុស្លីមអាស្ទុ់លុល-ស៊ុនណាស្ទុ់ខ្លះទិតៀនមុស្លីមស៊្ហីអាស្ទុ់ ដែលធ្វើបុណ្យរំលឹកខួបថ្ងៃព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام សោយព្រះទិវង្គត គឺថ្ងៃទី១០ ខែមូហារ៉មឬថ្ងៃអាស្ហ៊ូរ៉ ថាមិនត្រឹមត្រូវនឹងច្បាប់អ៊ីស្លាមដោយមានលេសនានាគ្មានហេតុផល ដល់ថ្នាក់ហ៊ានចោទបង្កាច់សំណាក់មុស្លីមស៊្ហីអាស្ទុ់ថាជាអ្នកសម្លាប់អ៊ីម៉ាំខ្លួនឯងផង ។

កូនសៀវភៅតូចនេះមានគោលបំណងឆ្លើយបំភ្លឺ ចំណុចសំខាន់ប្រាំជុំ វិញការកាន់មរណទុក្ខអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام ព្រះរាជនត្តារបស់ព្រះសាស្តាមូហ៊្ហាំម៉ាដ្ទុំ صلى الله عليه وآله មហាបុរសអ្នកអភិរក្សព្រះសាសនាអ៊ីស្លាមរបស់ព្រះអយ្យកោ صلى الله عليه وآله ព្រះអង្គ صلوات الله عليه والسلام បានគង់វង្សមកដល់សព្វថ្ងៃនេះ ។

សង្ឃឹមថាអស់លោកអ្នកបង្ហោះសម្តីរិះគន់តាម facebook នឹងស្វែងយល់ឲ្យក្រៃលជាងមុនៗអំពី "កោម" ខ្លួនឯងជាពិសេស ។ អល់ឡោះហ្វ៍ عز وجل បានដាក់ព្រះរាជបញ្ជាឲ្យតាមកោមទាំងបួននៅត្រង់ណា ? កាលពីព្រះសាស្តាមូហ៊្ហាំម៉ាដ្ទុំ صلى الله عليه وآله មានព្រះជន្មនៅឡើយ តើព្រះអង្គ صلى الله عليه وآله តាមកោមណា ? ម្តេចមិនតាមកោមដែលព្រះអង្គ صلى الله عليه وآله បានតាមកាលពីមុននោះ ? ឯកសារស្រាវជ្រាវអាស្ទុ់លី-ស៊ុនណាស្ទុ់មានច្រើនណាស់ ម្តេចក៏អស់លោកទាំងនោះមិនយកមកស្រាវជ្រាវ ?

លោកអ្នកចេះដឹងនិកាយ "អាស់លី ស៊ុនណាស់ វាល់-យ៉ាម៉ាអាស្ទុ់" ម្នាក់បានទិតៀននៅលើគេហទំព័រ facebook ថាស៊្ហីអាស្ទុ់ប្រារព្ធពិធីបុណ្យក៏ផ្សៀរនោះមិនត្រឹមត្រូវទេ ថាថ្ងៃបុណ្យក្នុងអ៊ីស្លាមមានតែពីរទេគឺ រ៉យ៉ា អ៊ីឌ្ទីល-ហ្វីទ្រី និង រ៉យ៉ា អ៊ីឌ្ទីល-អោដ្ហហ្វាប៉ុណ្ណោះ ដោយផ្អែកទៅលើសម្តី

របស់លោកសាវកម្នាក់ ឈ្មោះ អាណាស់ ប៊ិន ម៉ាលិក ។ មើលទៅ លោកអ្នកចេះដឹងម្នាក់នេះពុំបានមើលសៀវភៅ អាស្វលី ស៊ុនណាស់ ឈ្មោះ "អាល់-ប៊ីដ្ហាយ៉ាស់ វ៉ាន់-នីហ្វាយ៉ាស់ (اَلْبِدَايَةَ وَ اَلنِّهَايَة) ក្បាលទី ៧ របស់អ៊ីម៉ាំអ៊ីបន្ន កាស៊្សៀរទេដោយមានសម្ដីរបស់អាប៊ូ ហ៊្វូរ៉យ់ពោះត្ថ៍ជាអំណះអំណាងថាព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ប្រារព្ធពិធីបុណ្យកុំដៀរ ។ បើលោកអ្នកចេះដឹងម្នាក់នេះធ្វើការស្រាវជ្រាវឲ្យបានជ្រាលជាងនេះ លោកអ្នកចេះដឹងម្នាក់នេះច្បាស់ជាបានដឹងថាលោក អាណាស់ ប៊ិន ម៉ាលិក ជាអ្នកណាពិតប្រាកដ ។ សូមប្រាប់ដោយខ្លីថាលោក អាណាស់ ប៊ិន ម៉ាលិក កើតឃ្លង់នៅលើមុខបន្ទាប់ពីបានឆ្លើយអ៊ីម៉ាំអាលី عليه السلام ថាព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ពុំបានតែងតាំងព្រះអង្គ عليه السلام ជាអាមីរុល-មុមីនីនទេនៅឯកុំដៀរ ឃុមនោះនៅក្នុងក្រាំងសំណេរ "គីតាប អាល់-ម៉ាអារិហ្វ (كتاب المعارف) របស់លោកអ៊ីបន្ន គូតៃបាស់ (إبن قُتَيبة) ។ យើងនឹងឆ្លើយ អធិប្បាយលំអិតចំណុចនេះនៅពេលខាងមុខ ។ ម្យ៉ាងទៀត ថ្ងៃព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ប្រសូតនិងថ្ងៃព្រះអង្គ ﷺ សោយព្រះទិវង្គតនោះពុំមែនថ្ងៃបុណ្យទេ ? លោកអ្នកចេះដឹងម្នាក់នេះច្បាស់ជាព្រងើយកន្តើយអំពីរឿងនេះ ពីព្រោះសម្រាប់លោកអ្នកចេះដឹងម្នាក់នេះ វាពុំមែនជារឿងសំខាន់ទេដែលព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ បាននាំព្រះសាសនាអ៊ីស្លាមពីអល់ឡោះហ្វ៍ عَزَّ وَجَلَّ មកឲ្យមនុស្សនោះ ។ គួរតែដឹងព្រះគុណអល់ឡោះហ្វ៍ عَزَّ وَجَلَّ ផង ដែលបានបញ្ជូនមូហាំម៉ាដ្ឋ ﷺ មកនោះ ។ គួរតែដឹងថាពុំមានមូហាំម៉ាដ្ឋ ﷺ ទេ អ្វីៗក៏ពុំមានដែរ ។

សង្ឃឹមថាកូនសៀវភៅតូចនេះអាចធ្វើឲ្យមុស្លីមទាំងពីរប៉ែក បងប្អូនស៊ុន្នីនិងបងប្អូនស្ហ៊ីអាស់ និងបណ្ដាបងប្អូនមិនមែនមុស្លីមយល់ដឹងសាសនាអ៊ីស្លាមពិតប្រាកដប្រសើរឡើង ។



ជជែកអំពីការឈ្នះចាញ់ ។

គេរាប់ការឈ្នះឬការចាញ់របស់បុគ្គលក្នុងសង្គ្រាម ក្នុងការតស៊ូ ក្នុងការប្រយុទ្ធ ដោយផ្អែកលើគោលដៅដែលបុគ្គលបានថាមុនប្រយុទ្ធ ។ រឿងរ៉ាវការបាឡាអ៍បង្ហាញឲ្យឃើញថា យ៉ាស៊ីដ្ធមិនបានសម្រេចគោលដៅទេ ទោះបី ក្រោយពីបានសម្លាប់ព្រះសន្តអ៊ីម៉ាំហ៊្វូសៃន៍ عليه السلام ហើយក៏ដោយ ។ ផ្ទុយទៅវិញ ព្រះសន្តអ៊ីម៉ាំហ៊្វូសៃន៍ عليه السلام បានសម្រេចគោលដៅចម្បង គឺការពារសច្ចធម៌ ការកែតម្រូវនិងសាសនាអ៊ីស្លាម មិនឱនក្បាលដាក់បុគ្គលប្រើអំណាចផ្ដាច់ការទេ ។

## គោលដៅរបស់យ៉ាស៊ីដ្ធ

គោលដៅរបស់យ៉ាស៊ីដ្ធច្បាស់បំផុត គឺយកបៃអាស់ (بَيْعَة ការសច្ចាព្រមនៅក្រោមឱវាទ) ពីព្រះសន្តអ៊ីម៉ាំហ៊្វូសៃន៍ عليه السلام ក្នុងគោលបំណងធ្វើឲ្យខ៉ លីហ្វាស់[មិនស្របច្បាប់]របស់ខ្លួននឹង ។

គោលដៅរបស់ព្រះសន្តអ៊ីម៉ាំហ៊្វូសៃន៍ عليه السلام គឺមិនឱនក្បាលចុះញ៉មអំណាចផ្ដាច់ការទេ មិនឱនក្បាលចុះញ៉មមេដឹកនាំមិនស្របច្បាប់ទេ តែរក្សាគោលជំហរនៅលើមាគ៌ាត្រឹមត្រូវរបស់អ៊ីស្លាម ព្រះសាសនារបស់ព្រះអយ្យកោ ﷺ ព្រះអង្គ عليه السلام ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ។ ព្រះអង្គ عليه السلام មិនខ្លាចស្លាប់ទេ ។ "សម្រាប់ខ្ញុំ ការស្លាប់ជាព្រះគុណ" នេះគឺសម្ដីរបស់ព្រះសន្តអ៊ីម៉ាំហ៊្វូសៃន៍ عليه السلام ដាក់មុខកងទ័ពរបស់យ៉ាស៊ីដ្ធ ។

អ្នកណាឈ្នះ ? ខាងព្រះសន្តអ៊ីម៉ាំហ៊្វូសៃន៍ عليه السلام មិនឱនក្បាលចុះញ៉ម មិនសច្ចាស្មោះស្ម័គ្រយ៉ាស៊ីដ្ធឬបក្សពួកនានារបស់យ៉ាស៊ីដ្ធជាដាច់ខាត ។ គេពុំ

អាការយ៉ាហ្ញ៉ីលីយ៉ាស៊ូអារ៉ាប់នេះរស់ឡើងវិញ ជាប្រតិកម្មប្រកបដោយប្រសិទ្ធភាព ដើម្បីប្រជែងសិក្ខាបទអ៊ីស្លាមរបស់ព្រះសាស្តាមូហ៊ាំម៉ាដ៉ុំصلى الله عليه وآله ម្តងទៀត ។ កម្លាំងនៃប្រតិកម្មកំហូចនេះ តំណាងដោយលក្ខណៈបុគ្គលរបស់យ៉ាស៊ីដ៉ូដែលជាលក្ខណៈបុគ្គលកំហូចនិងមិនមែនអ៊ីស្លាមនោះ មាននូវឥទ្ធិពលល្មមសម្រាប់លុបបំបាត់ ឬយ៉ាងហោចណាស់ ធ្វើឲ្យខូចព្រះរាជសារដើមរបស់ព្រះសាស្តាមូហ៊ាំម៉ាដ៉ុំصلى الله عليه وآله ។ ហេតុដូច្នេះ នៅក្នុងសតិអារម្មណ៍របស់ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍صلوات الله عليه والسلام ពេលនេះត្រូវតែស្តារអ៊ីស្លាមសាសនាឡើងវិញ អ៊ីស្លាមសាសនាត្រូវតែមានចលនា ទប់ទល់នឹងប្រតិកម្មចាស់របស់ពួកអារ៉ាប់ ដូច្នេះវាទាមទារនូវការរៀបចំឡើងវិញទាំងស្រុង វាទាមទារនូវបដិវត្តន៍ទាំងស្រុង ។

បេសកកម្មរបស់ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍صلوات الله عليه والسلام ឋិតនៅលើការដាស់សតិសម្បជញ្ញៈជាជាងដោយការចាប់អាវុធកាន់និងការប្រយុទ្ធ ដោយគ្រាន់តែប្រើអំពើហិង្សា (កម្លាំងបាយ) និងសង្គ្រាម ។ ព្រះអង្គصلوات الله عليه والسلام មិនអាចសង្គ្រោះចលនានិងសតិសម្បជញ្ញៈអ៊ីស្លាមបានទេ ។ ព្រះអង្គصلوات الله عليه والسلام យល់ឃើញថាត្រូវដាស់ដួងចិត្តនិងវិញ្ញាណឲ្យកម្រើក ត្រូវធ្វើឲ្យអារម្មណ៍រំជើបរំជួល ។ ព្រះសន្តអ៊ីម៉ាំصلوات الله عليه والسلام បានសម្រេចចិត្តថាដើម្បីបានដល់គោលដៅនេះត្រូវតែឈឺចាប់ ត្រូវតែលះបង់ខ្លួន ត្រូវតែបូជាជីវិត តាមរយៈបេសកកម្មផ្នែកកាយនិងផ្នែកចិត្ត ដែលពុំធ្លាប់បានឃើញកាលពីមុនក្នុងប្រវត្តិសាស្ត្រមនុស្ស និងមិនដែលឃើញមានទៀតចាប់ពីពេលនោះមក ។

ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍صلوات الله عليه والسلام មិនបានតាំងចិត្តប្រយុទ្ធឈ្នះយ៉ាស៊ីដ៉ូ និងបក្សពួកដោយសង្គ្រាមយោធាទេ ។ ការពិតដែលហ៊្វូសែន៍صلوات الله عليه والسلام ត្រូវសម្លាប់សាវកទាំងអស់របស់ព្រះអង្គصلوات الله عليه والسلام ត្រូវសម្លាប់ ដោយកងទ័ពធំសម្បើមប្រដាប់អាវុធលើសទ័ពព្រះអង្គصلوات الله عليه والسلام នោះ ជាប្រការក្រៅសាច់រឿងសម្រាប់



## ហេតុអ្វីស៊ីអាស់ស្លៀកពាក់ខ្មៅក្នុងខែមូហារ៉ម ?

មូហារ៉មជាខែទីមួយនៃប្រក្រតិទិនអ៊ីស្លាម ។ ខែនេះជាខែដែលមុស្លីមស៊ីអាស់ចងចាំ នឹករំលឹកនិងកាន់ព្រះរាជមរណទុក្ខអ៊ីម៉ាំហ៊្វូសែន៍صلوات الله عليه والسلام ដែលជាព្រះសន្តអ៊ីម៉ាំស៊ីអាស់ទីបី និងជាព្រះរាជនត្តា (ចៅ) របស់ព្រះសាស្តាមូហ៊ាំម៉ាដ៉ុំصلى الله عليه وآله ។

## ការបាឡាអ៊្

ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍صلوات الله عليه والسلام និងសមាជិកគ្រួសារព្រះអង្គصلوات الله عليه والسلام ចំនួន ១៧ នាក់ រាប់ទាំងព្រះរាជបុត្រព្រះអង្គصلوات الله عليه والسلام ដែលជាទារកអាយុ ៦ ខែដែរ និងបណ្តាសាវកព្រះអង្គصلوات الله عليه والسلام ចំនួន ៩២ នាក់ទៀត (សរុប ១១០ នាក់) ត្រូវសម្លាប់នៅឯស្រុកការបាឡាអ៊្ ប្រទេសអ៊ីរ៉ាក់ ថ្ងៃទី ១០ ខែមូហារ៉ម ឬ "អាស៊ូរ៉" (عاشوراء) ឆ្នាំ ៦១ សករាជហ៊ីជ្រ៉ោះត៍ ឬឆ្នាំ ៦៨០ គ្រិស្តសករាជ ដោយកងទ័ពរបស់យ៉ាស៊ីដ៉ូ អ៊ីបនូ មូអាវីយ៉ាស៊ូ ដែលលើកខ្លួនឯងជាស្តេចខ៊លិហ្វសម័យនោះ ។

នេះជាឧត្តប្បត្តិហេតុគួរឲ្យរន្ធត់តក់ស្លុតនិងព្រៃផ្សៃបំផុត ដែលបានកើតឡើងទៅលើមហាបុរសសំខាន់បំផុតម្នាក់ក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ព្រមទាំងបណ្តាសមាជិកក្មេងៗគ្មានទោសនៃគ្រួសារព្រះអង្គصلوات الله عليه والسلام ។

សម័យឥឡូវនេះ ក្នុងពិភពលោកទាំងមូល ការស្លៀកពាក់ខ្មៅជាសញ្ញានៃការកាន់មរណទុក្ខ ។ ក្នុងពិធីបុណ្យសព មុស្លីមឬមិនមែនមុស្លីម អ្នកមានជំនឿនិងសាសនាផ្សេងគ្នាស្លៀកពាក់ខ្មៅជាសញ្ញាកាន់មរណទុក្ខ ។ តែពេលស៊ីអាស់ស្លៀកពាក់ខ្មៅ ដើម្បីធ្វើពិធីបុណ្យរំលឹកព្រះមរណភាព

របស់ព្រះរាជកុលដ្ឋាន عليهم السلام ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله អាស្វ៉លុល-បៃត៍ عليهم السلام ព្រះអង្គ صلى الله عليه وآله ដើម្បីអាល័យនិងសោកស្តាយព្រះសន្តអ៊ីម៉ាំហ៊្សែន صلوات الله عليه والسلام ពួកគេទិតៀន ដៀមដាម ។ ត្រឹមត្រូវទេ ?

## ឯកសារយោងដកស្រង់ពីសៀវភៅអាស្វ៉លុល-ស៊ុនណាស្វ៉

បុគ្គលមួយចំនួនសំណាក់អាស្វ៉លុល-ស៊ុនណាស្វ៉ថាស្ហ៊ីអ៊ាស្វ៉ចម្លែក មិនធម្មតា និយមជ្រុលក្នុងការស្លៀកពាក់ខ្មៅក្នុងខែមូហារ៉ម ។ ជាពិសេសលោកអ្នកនិពន្ធបង្គរឿងនិកាយស៊ុន្នី (អាស្វ៉លុល-ស៊ុនណាស្វ៉) ម្នាក់ឈ្មោះក៏ឌ្ហី ម៉ាស្វ៉ហ្វារ ហ៊្សែន ប្រទេសប៉ាគីស្ថាន សរសេរនៅក្នុងសៀវភៅលោកដែលមានចំណងជើងថា "ហ៊ូម ម៉ាតាំ គីយុន ណាហ៊ី ការទី" ថាសំលៀកបំពាក់ពណ៌ខ្មៅជាសំលៀកពាក់របស់ពួកនរក និងជាសំលៀកបំពាក់របស់ហ្សៀវអ៊្ហូន ។

ក៏ប៉ុន្តែ សៀវភៅរបស់អាស្វ៉លុល-ស៊ុនណាស្វ៉ល្បីៗច្រើនទៀតបញ្ជាក់ថាការស្លៀកពាក់ខ្មៅមិនទាស់ខុសទេ និងជាស៊ូណាត់មួយប៉ែកដែរ ។ ឧទាហរណ៍ លោក ត៍ាបារី អ្នកប្រវត្តិសាស្ត្រនិកាយស៊ុន្នី រាយការណ៍នៅក្នុងក្រាំងសំណេរ "តារីក្ហ" របស់លោក តមកពីអ៊ែស្មាស្វ៉ ប៊ិនទី អាប៊ូបាការ ថាព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله ផ្ទាល់តែម្តង បានពាក់អាវធំខ្មៅថ្ងៃចុងក្រោយបង្អស់ដែលព្រះអង្គ صلى الله عليه وآله បានរស់នៅលើផែនដី ។

ក្រាំងសំណេរ តារីក្ហ បាក់ដ្ឋាដ្ឋ (تاريخ بغداد) របស់លោក ខ្ហ៍ទីប បាក់ដ្ឋាឌ្ហី (الخطيب البغدادي) បានរាយការណ៍ថាយ៉្ហីបរ៉អ៊ីល عليه السلام ព្រះអគ្គទេវតា តែងតែមកជួបព្រះសាស្តា صلى الله عليه وآله ដោយពាក់អាវធំខ្មៅនិងឈ្នួតក្បាលពណ៌ខ្មៅ ។



នេះជាការយល់ច្រទ្បំទាំងស្រុងស្ទើរតែដោយចេតនា និងជាការប៉ាន់ស្មើរដោយមិនដឹងថា បេសកកម្មរបស់ព្រះសន្តអ៊ីម៉ាំហ៊្សែន صلوات الله عليه والسلام នោះគឺអ្វី ។ មិនមែនជាការប្រកួតនយោបាយ ឬជាការបះបោរយោធាទល់នឹងរបបអ៊្ហូម៉ៃយ៉ាស្វ៉ទេ ។ វាជាបេសកកម្មផ្នែកសច្ចធម៌ (ការពិត គឺព្រះធម៌) គឺសច្ចធម៌របស់អ៊ីស្លាម (អ៊ីស្លាមពិតឥតក្លែងក្លាយ) សច្ចធម៌ក្នុងការមានអល់ឡោះហ៊្វ عز وجل សច្ចធម៌នៃព្រះរាជសាររបស់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله សច្ចធម៌នៃអ៊ីម៉ាម៉ាត់និងវីឡាយ៉ាស្វ៉របស់ហ៊្សែន صلوات الله عليه والسلام ។

ពាក្យពេជន៍និងទង្វើទាំងអស់របស់ព្រះសន្តអ៊ីម៉ាំហ៊្សែន صلوات الله عليه والسلام មុនទៅដល់ការបាទ្បាអ៊ុំសឲ្យឃើញថាព្រះអង្គ صلوات الله عليه والسلام ដឹងច្បាស់ថា ជ័យជំនះដែលបានដោយកម្លាំងយោធានិងអំណាចជាជ័យជំនះមិនឋិតថេរ មិនបានយូរជាដាច់ខាត ព្រោះឥទ្ធិពលមួយទៀតអាចរំលំ អាចផ្តួលវាបាន ក្នុងពេលមិនយូរ ។ តែជ័យជំនះដែលបានដោយការឈឺចាប់ ដោយពលីកម្មនិងដោយការតស៊ូ ជាជ័យជំនះអមតៈ ដែលជិតជាប់ឥតរលុបបាននៅក្នុងសម្បជញ្ញៈនិងសតិអារម្មណ៍របស់មនុស្ស ។

នៅការបាទ្បាអ៊ុំ ដូច សៃយីដ្ឋ ហ៊ាសាន់ មុច្ចតាបា យ៉ាហ្វ៉រី ដែលជាប្រវត្តិវិទូស្ហ៊ីអ៊ាស្វ៉ បានកត់សម្គាល់នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា "The Origins and Early Development of Shi'a Islam (ដើមកំណើតនិងការរីកចម្រើនរបស់អ៊ីស្លាមស្ហ៊ីអ៊ាស្វ៉)" ថាដំណើរការនៃការប្រយុទ្ធនិងការតស៊ូរវាង "ចលនា" និង "ចលនាតបត" បានប្រព្រឹត្តទៅយ៉ាងសកម្ម ។ សិក្ខាបទអ៊ីស្លាមរបស់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله បានសម្រេច ដោយលុបបំបាត់យ៉ាហ៊្វីលីយ៉ាស្វ៉ (អវិជ្ជា) អភិរក្សនិយមហួសហេតុនិងការថយក្រោយមិនលូតលាស់របស់ពួកអារ៉ាប់វាលខ្សាច់ ។ តែក្នុងអំឡុងពេលហាសិបឆ្នាំ ក្រោយពីព្រះសាស្តាមូហ៊ាំម៉ាដ្ឋ صلى الله عليه وآله បានសោយព្រះទិវង្គត

សាស្ត្របានកត់សម្គាល់ថា ទាហានរបស់យ៉ាស៊ីដ្ធមិនទុកឲ្យបណ្ដាអ្នកដែលបានរួចជីវិតពីសមរភូមិបាដ្វាររស់រានមានជីវិតម្នាក់ឡើយ ។

បន្ទាប់ពីនោះ ឆ្នាំក្រោយមក ដូចត៉ូបារីនិងច្រើននាក់ទៀតបានរាយការណ៍ កងទ័ពរបស់យ៉ាស៊ីដ្ធបានចូលទៅក្នុងនគរម៉ាក់កាស់ បានវាយកាក់បាស់ពីលើកំពូលភ្នំក្បែរៗនោះ ដោយប្រើគ្រាប់បាញ់ដុតភ្លើងបណ្ដាលឲ្យឆេះក្រណាត់បាំងកាក់បាស់ ។

អាចស្មានមើលប្រតិកម្មរបស់ពិភពលោកមុស្លីមបានទេ បើអាមេរិកឬអង់គ្លេស ឬអ៊ីស្រាអែល ទម្លាក់គ្រាប់បែកទៅលើម៉ាក់កាស់និងម៉ាឌីណាស់ ធ្វើឲ្យឆេះកាក់បាស់ ? នឹងមានការឈឺចិត្ត នឹងមានកំហឹង នឹងមានការដើបបះបោរជុំគ្នា និងមានការវាយសងសឹកទៅលើប្រទេសខាងលិច ។ តែពេលមេដឹកនាំសាសន៍មុស្លីម ដែលតាំងខ្លួនឯងស្ដេចខ៉ូលិហ្វ ដុតកាក់បាស់ រំលោភស្ត្រី ប្លន់អ្នកស្រុកម៉ាឌីណាស់ គេសង្ឃឹមថាពួកមុស្លីមនឹងបំភ្លេចចោលរឿងនេះ មិនស្អប់បុគ្គននេះទេ មិនដាក់បណ្ដាសាបុគ្គលនេះទេ ?

## អ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام ចាញ់សមរភូមិការបាឡាអ៊ុំ មិនមែនទេ ?

នេះបើផ្អែកទៅលើព្រឹត្តិការណ៍ដែលយ៉ាស៊ីដ្ធរស់ ព្រះសន្តអ៊ីម៉ាំហ៊ូសែន صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ សោយព្រះទិវង្គត ។ អ្នកខ្លះថ្លែង ដោយខុស ថាយ៉ាស៊ីដ្ធ "ឈ្នះ" អ៊ីម៉ាំហ៊ូសែន صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ "ចាញ់" ។

### បេសកកម្មរបស់ព្រះសន្តអ៊ីម៉ាំហ៊ូសែន صلوات الله عليه والسلام



ក្រាំងសំណេរ តារីក៉ តូ៉បារី បានរាយការណ៍ថាគេបានឃើញជាញឹកញយ អ៊ូម៉ារ អ៊ីបនូ ខត្ត៉ប់ ស្ដេចខ៉ូលិហ្វទីពីររបស់អាស្វ់លុល-ស៊ុនណាស់ ដែលត្រូវអាស្វ់លុល-ស៊ុនណាស់ចាត់ទុកជាសាវកល្បីម្នាក់នោះ ស្លៀកពាក់ខ្មៅ - ទោះបីក្នុងរដូវក្ដៅខ្លាំងក៏ដោយ ! ពួកគេចង់ប្រៀបធៀបអ៊ូម៉ារជាមួយហ្សៀរអ៊ូនឬជាមួយពួកនរកមែនទេ ?

ត្រូវចងចាំទុកក្នុងចិត្តថាដែលស្ទីអាស៊ូស្លៀកពាក់ខ្មៅនោះ មិនមែនព្រោះតែពណ៌ខ្មៅជាពណ៌សាកលសម្រាប់ការអាឡោះអាល័យ ការសោកស្ដាយនិងការកាន់មរណទុក្ខតែម្យ៉ាងនោះទេ តែព្រះនាងស្មៃណាប់ ﷺ ព្រះរាជនត្តាស្រីរបស់ព្រះសាស្ដាមូហ៊ាំម៉ាដ្ធ ﷺ ធ្លាប់ស្លៀកពាក់ខ្មៅដើម្បីកាន់ព្រះមរណទុក្ខព្រះរៀម صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ព្រះនាង ﷺ គឺព្រះសន្តអ៊ីម៉ាំស៊្វសែន صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។

## ហេតុអ្វីស្ទីអាស៊ូយំច្រើនក្នុងខែមូហារ៉ម ?

មុស្លីមខ្លះថាយំ ជាពិសេសយំច្រើនពេក ជាកំហុស ជាការមិនសមហេតុផលនិងមិនមែនអ៊ីស្លាម ។

តែការយំយែកជាប៉ែកមួយនៃធម្មជាតិរបស់មនុស្ស និងជាមួយប៉ែករបស់អ៊ីស្លាម ។ ព្រះសាស្ដាមូហ៊ាំម៉ាដ្ធ ﷺ ធ្លាប់បានគាំទ្រឲ្យយំយែក ។ ព្រះអង្គ ﷺ មានព្រះវចនៈនៅក្នុងហាឌីស្សល្បីមួយថា៖ "លោកនឹងយំច្រើន សើចតិច បើអស់លោកដឹងថាអ្វីមកដល់ ។"[1]

[1] សូមមើលសាត្រា ស្វ៉ហ៊ិះហ៍ មុស្លីម ហាឌីស្ស ២៣៥៩

عَنْ أَنَسِ بْنِ مَالِكٍ، قَالَ بَلَغَ رَسُولَ اللَّهِ ﷺ عَنْ أَصْحَابِهِ شَىْءٌ فَخَطَبَ فَقَالَ " عُرِضَتْ عَلَىَّ الْجَنَّةُ وَالنَّارُ فَلَمْ أَرَ كَالْيَوْمِ فِي الْخَيْرِ وَالشَّرِّ وَلَوْ تَعْلَمُونَ مَا أَعْلَمُ لَضَحِكْتُمْ قَلِيلاً وَلَبَكَيْتُمْ كَثِيرًا " .

صحيح مسلم كتاب الفضائل باب توقير النبي وترك إكثار سؤاله عما لا ضرورة إليه أو لا يتعلق به تكليف وما

ព្រះគម្ពីរគួរអានមានច្រើនអាយ៉ាស់ថែងអំពីសារសំខាន់ និងការត្រឹមត្រូវក្នុងការបង្ហូរទឹកភ្នែក គឺ៖

وَإِذَا سَمِعُوا۟ مَآ أُنزِلَ إِلَى ٱلرَّسُولِ تَرَىٰٓ أَعْيُنَهُمْ تَفِيضُ مِنَ ٱلدَّمْعِ مِمَّا عَرَفُوا۟ مِنَ ٱلْحَقِّ ۖ يَقُولُونَ رَبَّنَآ ءَامَنَّا فَٱكْتُبْنَا مَعَ ٱلشَّٰهِدِينَ ﴿٨٣﴾

*កាលណាពួកគេបានឮអ្វីដែលគេបានបើកឲ្យព្រះសាស្ដា [របស់អល់ឡោះហ៍]ដឹង កាលនោះអ្នកឃើញភ្នែកពួកគេពោរពេញដោយទឹកភ្នែកព្រោះតែពួកគេស្គាល់ការពិត ។ ពួកគេថ្លែងថា៖ "ព្រះម្ចាស់អើយ អស់ទូលព្រះបង្គំជាខ្ញុំជឿហើយ ។ សូមព្រះមេត្តារាប់អស់ទូលព្រះបង្គំជាខ្ញុំបញ្ចូលក្នុងចំណោមអ្នកជាសាក្សី[ដែលចុះចូលចំពោះព្រះអង្គ]ផង ។*

[ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដ្ហាស់ អាយ៉ាស់ ៨៣ (៥:៨៣)]

ស៊ូរ៉ោះត៍ យូស៊ុហ្វ អាយ៉ាស់ ៨៤ ថែងអំពីយ៉ាក់គូបថា៖

وَتَوَلَّىٰ عَنْهُمْ وَقَالَ يَٰٓأَسَفَىٰ عَلَىٰ يُوسُفَ وَٱبْيَضَّتْ عَيْنَاهُ مِنَ ٱلْحُزْنِ فَهُوَ كَظِيمٌ ﴿٨٤﴾

*គេ (យ៉ាក់គូប) បានបែរចេញពីពួកគេហើយពោលថា៖ "ឱអនិច្ចា យូស៊ូហ្វអើយ !" ភ្នែកទាំងពីររបស់គេទៅជាស[ដោយទឹកភ្នែក]ដោយសារកើតទុក្ខ ។ គេបានអត់ធ្មត់សង្កត់ចិត្ត ។*

ការពិត ព្រះសន្តអ៊ីម៉ាំស៊ីអ្ាស់ទីបួន អ៊ីម៉ាំស្សែនុល-អ្ាប៊ីឌីន صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ បានលើកយកអាយ៉ាស់នេះរបស់ស៊ូរ៉ោះត៍ទី ១២ មកសំអាងកាលសាវកម្នាក់របស់ព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ បានសួរព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ថាហេតុអ្វីព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ យំច្រើន សោកស្ដាយព្រះបិតា صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ និងបណ្ដាបងប្អូនព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ដែលបានបូជាជីវិតថ្ងៃសោកនាដកម្មការបាឡាអ៊ុ៍នោះ ។





ទោះបីយ៉ាស៊ីដ្ធបានវាយឈ្នះ ឬមិនបានវាយឈ្នះនគរកុងស្តង់ទីណុបល៍ក៏ដោយ និយាយត្រង់ វាជារឿងផ្សេង ដោយសារអំពើឧក្រិដ្ឋនិងបាបធំដែលខ្លួនបានប្រព្រឹត្តក្រោយមកដោយឥតលាក់លៀម អស់មួយជីវិតកាលខ្លួនបានកាន់មុខតំណែងខ៉ុលីហ្វាស់ ។

បុគ្គលនិកាយវ៉ាហ្ហាប៊ីខ្លះចង់ធ្វើពុតជាថាមានការ "ខ្វែងមតិគ្នា" អំពីការបាឡាអ៊ុ៍ តែគិតយ៉ាងណាអំពីការកាប់សម្លាប់រង្គាលនៅម៉ាឌីណាស់ពីរឆ្នាំក្រោយសោកនាដកម្មការបាឡាអ៊ុ៍នោះ ? គិតយ៉ាងណាអំពីការដុតកាក់បាស់ដោយទ័ពរបស់យ៉ាស៊ីដ្ធតិចជាងបីឆ្នាំក្រោយមកនោះ ?

នៅក្នុងក្រាំងសំណេរ តារិក្ ត៍បារី ក្បាលទី ១៩ ប្រវត្តិវិទូល្បីល្បាញនិកាយស៊ុន្នី លោក ត៍បារី បានផ្ដល់ឯកសារបញ្ជាក់អំពីយ៉ាស៊ីដ្ធបានប្រព្រឹត្តិអំពើសាហាវយង់ឃ្នង និងអំពើរំលោភមិនអាចអត់ឱនឲ្យបានទាំងនេះនៅម៉ាឌីណាស់ និងម៉ាក់កាស់ ។

លោក អ៊ីបនូ អាស្សៀរ អ្នកប្រាជ្ញស៊ុន្នី បានសរសេរថាមុស្លីមរាប់ពាន់នាក់ត្រូវសម្លាប់និងត្រូវកាត់ក្បាលនៅម៉ាឌីណាស់ រាប់ពាន់នាក់ត្រូវចាប់ខ្លួនជាទាសៈទាសី ស្ត្រីលើសពីមួយពាន់នាក់ត្រូវចាប់រំលោភ ដោយកងទ័ពរបស់យ៉ាស៊ីដ្ធ ។ លោក អ៊ីបនូ គូតៃបាស់ (ابن قتيبة) បានរៀបរាប់ថាទារកត្រូវកន្ត្រាក់ពីដៃម្ដាយ ហើយត្រូវបោកទៅលើជញ្ជាំង សេះកងទ័ពរបស់យ៉ាស៊ីដ្ធត្រូវបើកដៃឲ្យនោមនៅក្នុង ម៉ាស់យ៊ិដ្ធ អាល់-ណាបាវី ម៉ាស់យ៊ិដ្ធរបស់ព្រះសាស្ដាមូហាំម៉ាដ់ صَلَّى اللهُ عَلَيْهِ وَآلِهِ នៅម៉ាឌីណាស់ ។

ស៊ហ្ាបាស់ បណ្ដាសាវក និងកូនចៅត្រូវកាប់សម្លាប់ទាំងអស់គ្នា ដោយកងទ័ពស៊ីរីនៅក្នុងការវាយលុកនគរម៉ាឌីណាស់នេះ ។ លោកអ្នកប្រវត្តិ

ជាមេបញ្ជាការកងទ័ពនេះ ។ មូអាវីយ៉ាស៊ូដាក់បញ្ជាលើយ៉ាស៊ីដ កូនប្រុសខ្លួន ឲ្យទៅចូលរួមក្នុងកងទ័ពនេះ ។ យ៉ាស៊ីដគេចវេះដោយយកលេសគ្រប់យ៉ាងឆ្លើយដោះសារ ដោយថាខ្លួនឈឺទៀតផង ។ លោក អ៊ីបនូ អាស៊្សៀរបានសរសេរថា មូអាវីយ៉ាស៊ូបានដោះលែងកូនប្រុសខ្លួនឲ្យរួចខ្លួនពីកំណែនចូលរួមក្នុងចម្បាំង ។ ក្នុងចម្បាំងទល់នឹងអាណាចក្ររ៉ូម៉ាំងបន្ទាប់ពីនោះ ទ័ពមុស្លីមរងជម្ងឺនិងការខ្វះខាតគ្រឿងផ្គត់ផ្គង់ច្រើន ។ ពេលដឹងឮភ័យវិបត្តិនេះ យ៉ាស៊ីដចាប់ផ្តើមច្រៀងថា៖ "ខ្ញុំមិនបារម្ភអំពីសេចក្តីលំបាករបស់ទាហាននៅឯហ្វារុកុដាណាទេ ដោយរងគ្រុនចាញ់និងភ័យវិបត្តិច្រើន ។ ខ្ញុំសប្បាយនៅទីនេះជាមួយភរិយាខ្ញុំ..."

មានចារទុកនៅក្នុងក្រាំងសំណេរ "មូរូជ អាល់-ស្ហាហ្ហាប់ (مُروجُ الذَّهَب)" ដោយប្រវត្តិវិទូ មាស់អ៊ូឌី (اَلْمَسْعُودِيّ) ដែរថា៖ "មូអាវីយ៉ាស៊ូបានទទួលដំណឹងអំពីដំណើរទៅមុខរបស់កងទ័ព ហើយបានផ្ញើដំណឹងនេះទៅប្រាប់យ៉ាស៊ីដ យ៉ាស៊ីដថា៖ "ដូច្នេះខ្ញុំត្រូវឲ្យមានពិធីជុបលៀងនៅឯផ្ទះ ដោយហៅមិត្តអ្នកផឹករបស់ខ្ញុំមកចូលរួម ។""

ដូច្នេះគេដឹងច្បាស់អាស្រ័យសម្តីខ្លួនឯងផ្ទាល់តែម្តង នៅក្នុងក្រាំងសំណេររបស់ប្រវត្តិវិទូស៊ុន្នី ថាយ៉ាស៊ីដមិនបានចូលរួមក្នុងកងទ័ពដែលបានវាយឈ្នះនគរកុងស្តង់ទីណុបល៍នោះទេ ថាហ្វាឌីស្ហចែងអំពីបណ្តារេហ៍ពលកងទ័ពនោះបានចូលឋានសួគ៌ យោលតាមលោកអ្នកប្រាជ្ញ ដូចជា អ៊ីបនូ ហ្វាយ៉ារ អាស់ក៏ទ្បានី ជាដើមនោះជាហាឌីស្ហអន់ឬខ្សោយ មិនអាចជឿបានទេជាបឋម ។

## អំពើឧក្រិដ្ឋរបស់យ៉ាស៊ីដ



ស្ហៃខ៍ ស៊ូឡៃម៉ាន អ៊ីបនូ អ៊ីបរ៉ហ៊ីម អាល់-គូន់ឌូស៊ី អាល់-ហាណាហ្វី (الشيخ سليمان بن ابراهيم القندوزى الحنفى) មានប្រសាសន៍នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា "យ៉ាណាប៊ិអ៊ អាល់-ម៉ាវ៉ាដ្ហាស៊ូ (ينابيع المودة)" ថា៖ "ការឈឺចាប់របស់អ៊ីម៉ាំហ៊ូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មិនត្រឹមតែជាការឈឺចាប់លើមនុស្សលោកតែត្យ៉ាងទេ សូម្បីតែពួកឃ្ជីន ពួកទេវតា ពួកសត្វចតុប្បាទ ពួកសត្វស្លាប មេឃនិងដើមឈើក៏យំសោកស្តាយដែរ ។ គេបានសរសេរថាមេឃបានយំសែសិបថ្ងៃបន្ទាប់ពីអ៊ីម៉ាំហ៊ូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ បានបូជាព្រះជន្ម ។"

## ហេតុអ្វីស៊ីអាស៊ូធ្វើ "ម៉ាក់តាំ (مَأْتَم)" ក្នុងខែមូហារ៉ម ?

"ម៉ាក់តាំ" ជាកិច្ចប្រតិបត្តិមួយក្នុងពិធីបុណ្យសព គឺការទះទ្រូងឬទះក្បាលខ្លួនឯងជានិមិត្តរូប ជាសញ្ញានៃការសោកសៅនិងការឈឺចាប់ ។

បណ្តាអ្នកទិតៀនរិះគន់ស៊ីអាស៊ូថាទង្វើនេះមិនមែនអ៊ីស្លាមទេ វាជាទង្វើជ្រុលនិយម ជាកម្អែលដែលសល់មកពីសម័យ "យ៉ាហ៊ីលីយ៉ាស៊ូ (جاهِلِيّة)" (គឺសម័យអវិជ្ជា) មុនអ៊ីស្លាមសាសនាដែលព្រះសាស្តាមូហាំម៉ាដ់ صَلَّى اللهُ عَلَيْهِ وَآلِهِ បានបំបាត់ចោល ។

តែការពិត "ម៉ាក់តាំ" មានដើមកំណើតចេញមកពីអ៊ីស្លាម មានមូលហេតុបញ្ជាក់ថាត្រឹមត្រូវ ។

### ភ័ស្តុតាងដកស្រង់មកពីក្នុងព្រះគម្ពីរគួរអាន

យើងបែរមករកព្រះគម្ពីរគួរអានវិញ ។ យើងឃើញមាននៅក្នុងស៊ូរ៉ោះត៍

អាស់-ស្ទារីយ៉ាត់ (៥១) អាយ៉ាស់ ២៩ ចែងអំពីព្រះនាងសារ៉ោះត៍ ព្រះមហេសីរបស់ព្រះសាស្ដាអ៊ីបរ៉ហ៊ីមﷺ ។ គេបានប្រាប់ថាព្រះនាងនឹងមានព្រះរាជបុត្រ គឺ៖

فَأَقْبَلَتِ ٱمْرَأَتُهُۥ فِى صَرَّةٍ فَصَكَّتْ وَجْهَهَا وَقَالَتْ عَجُوزٌ عَقِيمٌ ﴿٢٩﴾

*ភរិយាគេបានដើរចូលមកដោយស្រែកខ្លាំង ។ នាងបានវាយមុខខ្លួនឯង និយាយថា៖ "[ខ្ញុំជា]ស្រីជរាដែលមិនអាចមានកូនបាន !"* (៥១:២៩)

## ឯកសារយោងដកស្រង់មកពីសៀវភៅរបស់អាស់លុល-ស៊ុនណាស់

មានឯកសារយោងច្រើនស្ដីអំពីការប្រតិបត្តិពិធីម៉ាក់តាំ ក្នុងសម័យព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺនិងក្រោយសម័យព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ នៅក្នុងសៀវភៅរបស់អាស់លុល-ស៊ុនណាស់ ។

ឧទាហរណ៍ លោកអ្នកប្រាជ្ញអាស់លុល-ស៊ុនណាស់បានតំណាលថា សាវកម្នាក់របស់ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ ឈ្មោះ អ៊ូវ៉ៃស៍ អាល់-ការនី (أويس القرني) កាលលោកនៅឯប្រទេសយេមេនក្នុងចម្បាំងអ៊ូហ៊្វូដនោះ បានវាយបំបាក់ធ្មេញខ្លួនឯង កាលលោកឈឺចាប់ពេលបានឃើញព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺរងរបួសដោយបាក់ធ្មេញនៅក្នុងសមរភូមិអ៊ូហ៊្វូដ ។ ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺមិនបានរិះគន់ឬថ្កោលទោសលោកអ៊ូវ៉ៃស៍ទេ ដែលបានប្រព្រឹត្តបែបនេះ ។

បន្ទាប់មក ពេលចប់សង្គ្រាមអ៊ូហ៊្វូដ ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺបានចាត់ឲ្យមានការកាន់មរណទុក្ខមួយរយៈពេលឲ្យវរបុរសហ៊ាំស្សាស់ﷺ ឪពុកមាព្រះអង្គﷺដែលបានបូជាជីវិតនៅក្នុងលានប្រយុទ្ធ ដោយមានពិធីម៉ាក់តាំ ។ លោក ស្ហ៊ីបលី នុអ៊្មានី (شِبلی نُعمانی) បានតំណាលថា៖ "ព្រះសាស្ដាﷺ



នៅក្នុងក្រាំងសំណេរ ស្វ៍ហ៊ិះហ៍ ប៊ូខ៍រី មានហាឌីស្សព្រះសាស្ដាﷺមួយចែងថាបណ្ដាវេហ៍ពលនៃទ័ពដំបូងបង្អស់ដែលបានវាយយក "នគររបស់ព្រះចៅអធិរាជសេសារ (Caesar's city)" នគរកុងស្តង់ទីណុបល៍ គឺប្រទេសទួរគីសព្វថ្ងៃនេះ បណ្ដាវេហ៍ពលទាំងនោះនឹងបានចូលឋានសួគ៌ ។ បណ្ដាអ្នក "កាន់ជើង" យ៉ាស៊ីដប្រកាសតវ៉ាថាយ៉ាស៊ីដជាវេហ៍ពលមួយរូបរបស់កងទ័ពនេះ ដូច្នេះយ៉ាស៊ីដជាអ្នកបានចូលឋានសួគ៌ ។

ក៏ប៉ុន្តែ លោក អ៊ីបនូ ហាយ៉ារ អាស់ក៏ឡានី (ابن حجر العسقلاني) ដែលជាប្រវត្តិវិទូនិងជាអ្នកនិពន្ធជីវប្រវត្តិនិកាយស៊ុន្នីដ៏ល្បីល្បាញម្នាក់ មានប្រសាសន៍នៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា "ហ្វាត់ហ៍ អាល់-បារី (فَتْح اَلْبَارِي)" ថាហាឌីស្សនេះជាហាឌីស្សអន់ឬខ្សោយ ពុំនោះទេជាហាឌីស្សឥតបានការ (ស្ដីអំពី "នគររបស់ព្រះចៅអធិរាជសេសារ") ។ លោកបានលើកឡើងថាគេបានរាយការណ៍ថាមានតែពួកជនជាតិស៊ីរីទេដែលនិយាយហាឌីស្សនេះ គឺអស់បុគ្គលដែលប្រឆាំងអាលី صلوات الله عليه والسلام ដែលព្យាយាម "លើកជើង" និងគាំទ្រយ៉ាស៊ីដ អ៊ីបនូ មូអាវីយ៉ាស់ ។

ការពិតគឺកាលនោះយ៉ាស៊ីដស្រវឹងស្រាឡប់ស្មារតី មិនអាចទៅចូលរួមក្នុងសមរភូមិវាយនគរកុងស្តង់ទីណុបល៍បានទេ ។

នៅក្នុងសៀវភៅរបស់លោកក្បាលទី ៣ ដែលមានចំណងជើងថា "កាមីល ហ្វី អាល់-តារីក (الكامل في التاريخ)" លោក អ៊ីបនូ អាស្ស៊ៀរ (ابن الأثير) អ្នកប្រាជ្ញសម័យមុន មានប្រសាសន៍ថាមូអាវីយ៉ាស់បានចាត់បញ្ជូលកងទ័ពធំសម្បើមមួយទៅកាន់នគរព្រះចៅអធិរាជសេសារ (នគរកុងស្តង់ទីណុបល៍) បានតែងតាំងស៊ុហ្វយ៉ាន អ៊ីបនូ អោហ្វ៍ (سفيان بن عوف)

យោធាឬលើកទ័ពទៅច្បាំងទេ ។

លោក ឆាលស៍ ឌិកកិនស៍ (Charles Dickens) អ្នកនិពន្ធប្រលោមលោកដ៏ល្បីល្បាញ អ្នកជំនាញខាងពិភពលោកទិសខាងលិច បានកត់សម្គាល់ថា៖ "បើហ៊ូសែន៍ប្រយុទ្ធដើម្បីសេចក្ដីប្រាថ្នាលោកិយ ខ្ញុំមិនយល់ទេថាហេតុអ្វីបណ្ដាបងប្អូនស្រីរបស់លោក និងបណ្ដាកូនក្មេងទៅតាមលោក ។ អ្វីដែលសមហេតុផល គឺលោកបូជាជីវិតដើម្បីអ៊ីស្លាមតែម្យ៉ាង ។"

គួរឲ្យពិបាកចិត្ត សូម្បីតែអ្នកមិនមែនមុស្លីមដូចលោកឌិកកិនស៍និងលោកគិបបុនក៏អាចទទួលស្គាល់និងទទួលយកបានយ៉ាងងាយ អ្វីដែលព្រះសន្តអ៊ីម៉ាំហ៊ូសែន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُអនុវត្តិបានសម្រេចនៅការបាឡាអ៊័ ចំណែកឯមុស្លីមសន្នឹកសន្ធាប់នៅតែមិនដឹងឬសង្ស័យពលីកម្មកំពូលរបស់ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។

## ស៊ុំអាស៊ុំមិននិយាយបំផ្លើសពេកទេថាយ៉ាស៊ីដអាក្រក់នោះ ?

បណ្ដាអ្នកអត់ទោសឲ្យយ៉ាស៊ីដ ក្នុងសំណាក់អាស្ហ៍លុល-ស៊ុនណាស៊ ប្រកាសអះអាងថាត្រូវឲ្យយ៉ាស៊ីដរួចខ្លួនពីការរិះគន់ ព្រោះយ៉ាស៊ីដបានចូលរួមក្នុងការវាយយកបាននគរ កុងស្តង់ទីណុបល៍ (القُسْطَنْطَينِيّة Constaninople) គេគោរពនិងកោតសរសើរប្រការនេះ ព្រោះព្រះសាស្ដាមូហាំម៉ាដ់ﷺបានទាយទុកមុនស្រេចហើយ ។

តែរឿងនេះជារឿងមិនពិត សម្របសម្រួលដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន (អ៊ូម៉ៃយ៉ាស៊) ។

### ឯកសារយោងដកស្រង់ពីក្រាំងសំណេររបស់អាស្ហ៍លុល-ស៊ុនណាស៊



បានដាក់បញ្ជាឲ្យមិត្តនៅស្រុកម៉ាឌីណាស៊ ទៅកាន់លំនៅរបស់របុរសហ្ស៊ាំស៊ា៊ស៊﵁ ដើម្បីទៅយំសោកស្ដាយលោក﵁ ។"

មានឧទាហរណ៍មួយទៀតបានមកពី អ៊ែស្ហាស៊ ប៊ិនទី អាប៊ូ បាការ ។ លោកអ្នកប្រាជ្ញអ៊ូឡាម៉ាសម័យមុនឈ្មោះ អ៊ីបនូ កាស៊ៀរ (ابن كثير) បានតំណាលតមកពីអ៊ែស្ហាស៊ ថាកាលព្រះសាស្ដាមូហាំម៉ាដ់ﷺចូលព្រះទិវង្គត អ៊ែស្ហាស៊បានថា៖ "ខ្ញុំបានងើបឡើងដោយវាយទ្រូងខ្លួនឯង ទះមុខខ្លួនឯងជាមួយស្រ្តីឯទៀត ។"

លោកអ៊ូឡាម៉ាឈ្មោះ មុតតាគ្គី អាល់-ហ៊ីនឌី (المتقي الهندي) អ្នកប្រាជ្ញស៊ុន្នីតំណាលថា៖ "កាលហាដ់រ៉ោះត៍ (حَضْرَة) អ៊ុម៉ារបានឮថាលោក នុអ៊ុ័ម៉ាន អ៊ីបនូ មុក្ករីន (النعمان بن مقرن) ស្លាប់ លោកបានវាយក្បាលខ្លួនឯង ព្រមទាំងស្រែកថា៖ "នុអ៊ុ័ម៉ានស្លាប់ គួរឲ្យអាណោចអាធ័មណាស់ ។""

អ៊ុម៉ារអាចធ្វើម៉ាកុំតាំឲ្យនុអ៊ុ័ម៉ាន មេទ័ពរបស់គាត់ដែលបានស្លាប់ក្នុងសមរភូមិនោះបាន តែពេលស៊ីអាស៊ធ្វើដូច្នេះដែរឲ្យព្រះសន្តអ៊ីម៉ាំហ៊ូសែន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ព្រះរាជនត្តាصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُជាទីស្រឡាញ់របស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ គេចងចិញ្ចើមដាក់ (គឺមិនយល់ព្រម) បែរជាហៅថាជាទង្វើកែប្រែ (ឬប៊ីដអាស៊ بدعة) វិញ ។ តើវាសមហេតុផលដែរឬទេ ?

## នេះជាការបង្ហាញ "អាទ្បាំ (عَلَم)" ដែលច្បាប់ហាម និងជាអំពើស៊ីរីកមួយបែបមែនទេ ?

### និមិត្តរូបរបស់សាសនា

"អាុទ្បាំ (عَلَم)" ភាសាអារ៉ាប់ មានន័យថា "ទង់", "គំរូ (ខ្នាត)" ឬ "សញ្ញា" ។ វាជានិមត្តរូប យើងសូមបញ្ជាក់ថា ស្ហ៊ីអាុស្ហ់មិនគោរពបូជាវត្ថុទាំងនេះទេ ។

ពិតមែន សាសនាទាំងអស់សុទ្ធតែមាននិមិត្តរូប ។ បើពុំមាននិមិត្តរូបឬពិធីទេ ក៏ពុំមានសាសនាដែរ ។ ចូរក្រឡេកមើលទៅសាសនាធំៗជាងគេក្នុងពិភពលោក គ្រិស្តសាសនា សាសនាយ៉ាហ្វ៊ូឌី សាសនាហ៊ីនឌូ ទាំងអស់នេះសុទ្ធតែមាននិមិត្តរូបនៃសាសនា ។

អាុទ្បាំមានអត្ថន័យខាងចិត្តឬវិញ្ញាណសម្រាប់មុស្លីមស្ហ៊ីអាុស្ហ់ ។ ទោះបីស្ហ៊ីអាុស្ហ់ទាំងអស់ រាប់បញ្ចូលស្ហ៊ីអាុស្ហ់ប្រទេសអ៊ីរ៉ាក់ អ៊ីរ៉ង់ អាហ្វ៉ានីស្តង់ លីបង់ អាសែរបៃយ៉ង់ ទួរគី បាស្ហ័រែន អារ៉ាប៊ី សាអ៊ូឌីនិងស៊ីរីដែរ មាននូវអាុទ្បាំមួយបែបឬមួយបែបផ្សេងក៏ដោយ នៅក្នុងក្បួនហែអាុស្ហ៊ូរ៉របស់ពួកគេ គឺបុណ្យរំលឹកព្រះសន្តអ៊ីមុាំហ៊្វាសែន៍صلوات الله عليه والسلامសោយព្រះទិវង្គត ចំណែកឯក្បួនហែអាុស្ហ៊ូរ៉នៅឯឧបទ្វីបឥណ្ឌាមានបែបមួយផ្សេង មានអត្ថន័យជ្រៅជាង អត្ថន័យខាងចិត្តឬវិញ្ញាណ ។

យកតាមប្រវត្តិសាស្រ្ត ព្រះរាជវង្សរបស់ព្រះសាស្តាមូហ៊ាំម៉ាដ់صلى الله عليه وآلهមានទង់ (អាុទ្បាំ) មួយគត់ដែលមានតែប្រជាជាតិ បានី ហ្វាស្ហ៊ីម មួយគត់ជាអ្នកតំណាង ។ គេជ្រើសរើសសមាជិកព្រះរាជវង្សថ្លៃថ្លានេះជាអ្នកកាន់ទង់នេះក្នុងការធ្វើដំណើរឬក្នុងសមរភូមិ ។ កាលពីដើមទង់នេះមានពណ៌បៃតង ត្រូវប្រគល់ឲ្យទៅព្រះសន្តអ៊ីមុាំអាុលី ប៊ិន អាប៊ូ ត៍លិបصلوات الله عليه والسلام អ៊ីមុាំស្ហ៊ីអាុស្ហ់ទីមួយ ដោយព្រះសាស្តាមូហ៊ាំម៉ាដ់صلى الله عليه وآلهផ្ទាល់ ។ អ៊ីមុាំអាុលីصلوات الله عليه والسلامបានប្រគល់អាុទ្បាំនេះឲ្យទៅព្រះរាជបុត្រទាំងពីររបស់ព្រះអង្គصلوات الله عليه والسلام អ៊ីមុាំហ៊ាសាន់صلوات الله عليه والسلام ក្រោយមកឲ្យទៅអ៊ីមុាំហ៊្វាសែន៍صلوات الله عليه والسلام ហើយព្រះអង្គصلوات الله عليه والسلامបានប្រគល់វាឲ្យទៅប្អូនប្រុសឪពុកមួយរបស់ព្រះអង្គصلوات الله عليه والسلام ឈ្មោះ



ដែលមានវចនៈទេថាព្រះអង្គصلوات الله عليه والسلامចង់បានអំណាចឬអាជ្ញា ។ ព្រះអង្គصلوات الله عليه والسلامបានបញ្ជាក់ឲ្យដឹងច្បាស់ហើយថាព្រះអង្គصلوات الله عليه والسلامចង់កែតម្រូវ ។ បេសកកម្មរបស់ព្រះអង្គصلوات الله عليه والسلامគឺស្តារការប្រតិបត្តិអ៊ីស្លាមនៅក្នុងសហាគមន៍អ៊ីស្លាម ។

ពុំមានក្រាំងសំណេរណាមួយឡើយ ចែងថាព្រះសន្តអ៊ីមុាំហ៊្វាសែន៍صلوات الله عليه والسلامទាមទារអំណាច នៅក្នុងកិច្ចសន្ទនាណាមួយជាមួយសមាជិកណាមួយរបស់រាជរដ្ឋាភិបាលរបស់យ៉ាស៊ីដ្ឋឬជាមួយកងទ័ព ទោះបីមួយដងក៏ដោយ ។ ព្រះអង្គصلوات الله عليه والسلامបានបដិសេធយកយុទ្ធជនសំខាន់ៗរបស់ព្រះអង្គصلوات الله عليه والسلامទៅប្រយុទ្ធនៅការបាទ្បាអ៊្រជាមួយព្រះអង្គصلوات الله عليه والسلامដែរ ។ យុទ្ធជនពូកែៗនិងក្លាហានដាច់គេប្រាំនាក់របស់ព្រះអង្គصلوات الله عليه والسلامគឺៈ អាុប់បាស់, មុស្លីម អ៊ីបនូ អាុគ៊ីល, អាុប់ឌុលឡោះហ្ន៍ អ៊ីបនូ យ៉ាក់ហ្វារ, មូហ៊ាំម៉ាដ់ ហាណាហ្វីយ៉ាស្ហ់ និងកូនប្រុសបង្កើតរបស់លោក, និង ស៊ែន៍ អាល់-អាុប៊ីឌីនصلوات الله عليه والسلام ព្រះសន្តអ៊ីមុាំទីបួន ។ មូអាុវីយ៉ាស្ហ់ធ្លាប់តែនិយាយថាយុទ្ធជនទាំងប្រាំនាក់នេះគ្រប់គ្រាន់ណាស់សម្រាប់វាយយកទ្វីបអារ៉ាប់ទាំងមូល ។ ក៏ប៉ុន្តែ ក្នុងថ្ងៃអាុស្ហ៊ូរ៉ មានតែយុទ្ធជនម្នាក់គត់ ក្នុងចំណោមយុទ្ធទាំងប្រាំនាក់នេះ ចូលរួមជាមួយព្រះសន្តអ៊ីមុាំហ៊្វាសែន៍صلوات الله عليه والسلامដើម្បីប្រយុទ្ធ គឺអាុប់បាស់ ទុកជាដូច្នេះក៏ដោយក៏លោកត្រូវហាមប្រយុទ្ធ ។ តើអាកប្បកិរិយានេះដូចអាកប្បកិរិយារបស់មេបញ្ជាការយោធាទេ ? ជាបុរសដែលចូលចិត្តធ្វើសង្គ្រាមនិងការបង្ហូរឈាម ?

ចូរកុំភ្លេចឡើយថា ព្រះសន្តអ៊ីមុាំហ៊្វាសែន៍صلوات الله عليه والسلامបាននាំបណ្តាស្ត្រីនិងក្មេងៗធ្វើដំណើរទៅកាន់គូហ្វាស្ហ់ជាមួយព្រះអង្គصلوات الله عليه والسلام ផ្ទុយនឹងការណែនាំរបស់អ្នកចាស់ទុំដូចជា អាុប់ឌុលឡោះហ្ន៍ អ៊ីបនូ អាប់បាស់ ជាដើម ។

ព្រះអង្គصلوات الله عليه والسلامចង់បង្ហាញពិភពលោក ថាព្រះអង្គصلوات الله عليه والسلامមិនប្រតិបត្តិការ

អ៊ីម៉ាំហាសាន់صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُវិញ បើព្រះសន្តអ៊ីម៉ាំហាសាន់صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُសោយព្រះទិវង្គត មុខតំណែងនេះបានទៅព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។ អាស្រ័យហេតុនេះ ដែលព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُបះបោរប្រឆាំង យ៉ាស៊ីដ្ អ៊ីបនូ មូអាវីយ៉ាស្ទ៍នោះ ព្រោះព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមានសិទ្ធិពេញទីធ្វើបែបនេះ ។ ព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُជាស្ដេចខ្ញុំលិហ្វស្របតាមច្បាប់ ឯយ៉ាស៊ីដ្ជាបុគ្គលប្លន់មុខតំណែងរបស់គេ ។

## បេសកកម្មរបស់ព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صلوات الله عليه والسلام

សូមរំលឹកឡើងវិញ យោលតាមហាឌីស្សរបស់ព្រះសាស្ដាមូហាំម៉ាដ្صَلَّى اللهُ عَلَيْهِ وَآلِهِ ថ្លែងដោយអ៊ុឡាម៉ាស៊ុន្នីនិងអ៊ុឡាម៉ាស្ស៊ីអាស្ទ៍ ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِមានព្រះវចនៈថា៖ "ហាសាន់صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُនិងហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُជា "ព្រះសន្តអ៊ីម៉ាំ អង្គុយក្ដី ឈរក្ដី" ជា "ព្រះអគ្គប្រមុខរបស់យុវជនឋានសួគ៌""[2] ។

បេសកកម្មរបស់ព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មិនមែនបេសកកម្មយោធាទេ ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមិនមានគោលបំណងប្រយុទ្ធនឹងយ៉ាស៊ីដ្ ឬច្បាំងប្រជាជាតិអ៊ូម៉ៃយ៉ាស្ទ៍ទេ ។ ព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُមានវចនៈច្បាស់លាស់មុនចាកចេញពីម៉ាឌីណាស្ទ៍ថា៖ "ខ្ញុំصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُចាកចេញពីទីនេះដើម្បីកែតម្រូវអ៊ុមម៉ាត្ទ៍ (បណ្ដាអ្នកតាម) របស់ព្រះអយ្យកោصَلَّى اللهُ عَلَيْهِ وَآلِهِខ្ញុំصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។" ព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُពុំ

[2] សូមមើលសាត្រា "យ៉ាមិអ៊ុ៍ អាត់-តៀរមីស៊ី (جامع الترمذي)"

حَدَّثَنَا مَحْمُودُ بْنُ غَيْلاَنَ، قَالَ حَدَّثَنَا أَبُو دَاوُدَ الْحَفَرِيُّ، عَنْ سُفْيَانَ، عَنْ يَزِيدَ بْنِ أَبِي زِيَادٍ، عَنِ ابْنِ أَبِي نُعْمٍ، عَنْ أَبِي سَعِيدٍ الْخُدْرِيِّ، رضى الله عنه قَالَ قَالَ رَسُولُ اللَّهِ ﷺ " الْحَسَنُ وَالْحُسَيْنُ سَيِّدَا شَبَابِ أَهْلِ الْجَنَّةِ " .

حَدَّثَنَا سُفْيَانُ بْنُ وَكِيعٍ، قَالَ حَدَّثَنَا جَرِيرٌ، وَمُحَمَّدُ بْنُ فُضَيْلٍ، عَنْ يَزِيدَ نَحْوَهُ . قَالَ أَبُو عِيسَى هَذَا حَدِيثٌ حَسَنٌ صَحِيحٌ . وَابْنُ أَبِي نُعْمٍ هُوَ عَبْدُ الرَّحْمَنِ بْنُ أَبِي نُعْمٍ الْبَجَلِيُّ الْكُوفِيُّ وَيُكْنَى أَبَا الْحَكَمِ .



អាប់បាស់ ប៊ិន អាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។ អាប់បាស់ ប៊ិន អាលីصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُបានកាន់ទង់នេះជាប់លុះដាច់ដង្ហើមក្នុងសមរភូមិការបាទ្បាអ៊ុ៍ ។

ចូរចងចាំថា គ្រប់ប្រទេសនិងក្រុមសុទ្ធតែមាននិមិត្តរូបឬទង់មួយ មិនចំពោះតែស្ស៊ីអាស្ទ៍ទេ ។ អាឡាំជាសញ្ញា គ្រាន់តែជានិមិត្តរូបប៉ុណ្ណោះរបស់ព្រះរាជកុលដ្ឋានព្រះសាស្ដាមូហាំម៉ាដ្صَلَّى اللهُ عَلَيْهِ وَآلِهِ អាស្ទ៍លុល-បៃត៍عَلَيْهِمُ السَّلَامُរបស់ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِهِ ។

អ្នកខ្លះមិនពេញចិត្តនឹងរបៀបបង្កើតអាឡាំទេ ។ តែត្រូវបើកសិទ្ធិឲ្យសហគមន៍នីមួយៗ ។ គេមិនត្រូវបង្ខំអ្នកដទៃឲ្យអនុវត្តពិធីប្រតិបត្តិទាំងនេះទេ ឬបង្ខំអ្នកដទៃឲ្យបោះបង់ចោលពិធីប្រតិបត្តិបែបនេះទេ ។ ពិធីប្រតិបត្តិទាំងនេះជាប៉ែកមួយមិនអាចចោលបាន ក្នុងការរំលឹក ចងចាំមិនភ្លេចរឿងរហូតសោកនាដកម្មការបាទ្បាអ៊ុ៍និងព្រះសន្តអ៊ីម៉ាំហ៊ូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។ ពិធីប្រតិបត្តិទាំងនេះមិនមែនជាការចាំបាច់ឬវ៉ាយ៉ិបទេ ។ អកុសល បុគ្គលខ្លះមានះប្រទូសប្រឆាំង បណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុងការទាស់ទែងថ្មីនិងឥតខ្លឹមសារ ។ សំខាន់គឺត្រូវយល់មូលហេតុនិងរឿងរ៉ាវនៅពីក្រោយពិធីប្រតិបត្តិនេះ ។

## ភ័ស្តុតាងដកស្រង់មកពីក្នុងព្រះគម្ពីរគួរអាន

លើកនេះទៀត យើងអាចយកព្រះគម្ពីរគួរអានជាឯកសារយោងដើម្បីយល់ដឹងតម្លៃនិងឥទ្ធិពលរបស់និមិត្តរូបនៅក្នុងសាសនាអ៊ីស្លាម ។ នៅក្នុងស៊ូរ៉េាះត៍យូស៊ុហ្វ (ស៊ូរ៉េាះត៍ ១២) អាយ៉ាស្ទ៍ ៩៣ ព្រះសាស្ដាយូស៊ុហ្វعَلَيْهِ السَّلَامُ មានព្រះវចនៈថា៖

ٱذْهَبُوا۟ بِقَمِيصِى هَـٰذَا فَأَلْقُوهُ عَلَىٰ وَجْهِ أَبِى يَأْتِ بَصِيرًا وَأْتُونِى بِأَهْلِكُمْ أَجْمَعِينَ ﴿٩٣﴾

*ចូរអស់លោកយកអាវខ្ញុំនេះទៅដាក់លើមុខឪពុកខ្ញុំ លោកនឹងមើលឃើញវិញដូចដើម ហើយចូរអស់លោកនាំគ្រួសារអស់លោកមករកខ្ញុំ ។*

គួរឲ្យស្តាយ មុស្លីមនិកាយអាស់លុល-ស៊ុនណាស់ភាគច្រើន ដូចជានិកាយវ៉ាហ្ហាប៊ីនៃប្រទេសអារ៉ាប៊ី សាអ៊ូឌី ជាដើម ប្រព្រឹត្តចំពោះនិមិត្តរូបដូចជានិមិត្តរូបនោះត្រូវច្បាប់ហាម ជាអ្វីដែលហារ៉ាំ ដោយគ្មានអំណះអំណាងនៅក្នុងព្រះគម្ពីរគួរអានឬនៅក្នុងហាឌីស្សព្រះសាស្តា صَلَّى اللهُ عَلَيْهِ وَآلِهِ បណ្តាលឲ្យកើតមានការយល់ខុសឥតប្រយោជន៍ និងខូចខាតដល់វប្បធម៌ ដល់ប្រវត្តិសាស្ត្រអ៊ីស្លាម ។ ទីកន្លែងប្រវត្តិសាស្ត្រសំខាន់ច្រើនត្រូវកម្ទេចចោលនៅមួយកន្លែងតែម្តង ដូចជានៅម៉ាក់កាស់និងម៉ាឌីណាស់ជាដើម ដោយសារជំនឿមិនត្រឹមត្រូវថានិមិត្តរូបត្រូវច្បាប់ហាម ជាសញ្ញានៃអំពើស៊ីរីក (ហ៊ុនហាយជាមួយអល់ឡោះហ៊ូ عَزَّ وَجَلَّ) ។

## មិនមែនពួកស៊ីអាស់ទេជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់ អ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام ?

នេះគឺការចោទប្រកាន់គ្មានភ័ស្តុតាងធ្ងន់ណាស់ ទៅលើសំណាក់មុស្លីមស៊ីអាស់ដោយបុគ្គលដែលបានទទួលពត៌មានខុស ឬបុគ្គលដែលមានបំណងអាក្រក់ ។

### ការអញ្ជើញទៅកាន់ស្រុកគូហ្វាស់

គេថាពួកស៊ីអាស់ស្រុកគូហ្វាស់ជាអ្នកផ្ញើសំបុត្រទៅព្រះសន្តអ៊ីម៉ាំ ហ៊្វូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ សូមអញ្ជើញព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មកកាន់ស្រុកគូហ្វាស់ ថាបន្ទាប់មកពួកស៊ីអាស់នេះបានក្បត់ព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។ ព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ បានចាត់



ឆ្នាំ ៦៨០ គ្រិស្តសករាជ ថាព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ និងបណ្តាអ្នកតាមព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ត្រូវកាប់សម្លាប់រង្គាលនៅកណ្តាលវាល ក្រោយពីត្រូវបង្អត់បាយនិងទឹក ថាកងទ័ពរបស់យ៉ាស៊ីដ្ឋ អ៊ីបនូ មូអាវីយ៉ាស់ជាអ្នកទទួលខុសត្រូវអំពើហិង្សាឧក្រិដ្ឋនេះ ។

## អ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام មិនខុសទេដែលបះបោរប្រឆាំងយ៉ាស៊ីដ្ឋ អ៊ីបនូ មូអាវីយ៉ាស់ អ្នកគ្រប់គ្រងសម័យព្រះអង្គ صلوات الله عليه والسلام នោះ ?

ឥស្សរជននិកាយស៊ុន្នីខ្លះសម័យឥឡូវ ដូចជាលោក ស្សាកៀរ ណាអ៊ីក (ذاکر نائیک) ជនជាតិឥណ្ឌាជាដើមបានស្រែកប្រកាសថាសោកនាដកម្មការបាឡាអ៊ុំជា "សង្គ្រាមនយោបាយ" ដែលបានកើតឡើងដោយសារតែ "ខ្វែងមតិគ្នា" តែម្យ៉ាងរវាងយ៉ាស៊ីដ្ឋនិងអ៊ីម៉ាំហ៊្វូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ។

បណ្តាអ្នកប្រាជ្ញមជ្ឈឹមសម័យដូចជា អ៊ីបនូ តៃមីយ៉ាស់ បុព្វបុរសខាងមនោគមវិជ្ជារបស់និកាយវ៉ាហ្ហាប៊ីជាដើម ប្រកែកថាអ៊ីម៉ាំហ៊្វូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មាន "គោលបំណងនយោបាយ" ព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ជា "បុគ្គលបះបោរ" ។ នេះគឺអ្វីដែលមិនសមហេតុផលនិងជាការប្រមាថមើលងាយដែរ ។

### យ៉ាស៊ីដ្ឋមិនមែនមេដឹកនាំស្របច្បាប់ទេ

ខលក្ខខណ្ឌក្នុង "សន្ធិសញ្ញាសន្តិភាព" ជាមួយព្រះសន្តអ៊ីម៉ាំទីពីរ ស្តេចខ៉លិហ្វទីប្រាំ គឺព្រះសន្តអ៊ីម៉ាំហាសាន់ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មូអាវីយ៉ាស់មិនមានសិទ្ធិលើកយ៉ាស៊ីដ្ឋជាអ្នកស្នងខ្លួនទេ ពោលគឺ ជាស្តេចខ៉លិហ្វបន្ទាប់ពីខ្លួន ។ យោលតាមខលក្ខខណ្ឌច្បាស់លាស់នៃសន្ធិសញ្ញាសន្តិភាពនោះ មុខតំណែងស្តេចខ៉លិហ្វរបស់អស់មុស្លីមត្រូវសន្មតថា ត្រឡប់មកបានលើព្រះសន្ត

ការបាឡាអ៊ំផ្ទាល់តែម្តង និងអំពីអ្នកស្លាប់នានា ។ ក្រាំងប្រវត្តិសាស្ត្រក្បាលទី ១៩ នេះថ្លែងអំពីពាក្យពេជន៍របស់បណ្តាសាក្សីផ្ទាល់ភ្នែកដែរ ។

## អ្នកប្រវត្តិសាស្ត្រផ្សេងៗឯទៀត

ប្រវត្តិវិទូទិសខាងលិចក៏បានរាយការណ៍អំពីព្រឹត្តិការណ៍ការបាឡាអ៊ំដែរ ។ លោក អេដវ៉ាដ់ គីបបុន (Edward Gibbon) ប្រវត្តិវិទូអង់គ្លេសសតវត្សទី ១៨ បានសរសេរនៅក្នុងអត្ថបទ "Decline and fall of the Roman Empire (ការអត់ថយនិងការរលំរបស់អាណាចក្ររ៉ូម៉ាំង)" ថា៖ "នៅក្នុងសម័យកាលនិងបរិយាកាសដ៏យូរអង្វែង ទិដ្ឋភាពខ្លោចផ្សានៃការស្លាប់របស់ហ៊ូសែន៍នឹងធ្វើឲ្យអ្នកអានសោះអង្គើយបំផុត កើតមានអារម្មណ៍អាណិតអាសូរ ។"

ប្រវត្តិវិទូសតវត្សទី ១៩ ជាតិអេកូសឈ្មោះ តូម៉ាស់ ការឡៃល៍ (Thomas Carlyle) សរសេរថា៖ "មេរៀនដែលយើងដកស្រង់បានពីសោកនាដកម្មការបាឡាអ៊ំគឺ ហ៊ូសែន៍និងបណ្តាបក្សពួកជាអ្នកមានជំនឿចំពោះព្រះឥតប្រែប្រួល ។ ពួកគេបានបង្ហាញឲ្យឃើញថាគេមិនយកចំនួនច្រើនទេកាលណាគេស្គាល់ការពិត ស្គាល់ប្រការខុស (ដឹងបុណ្យ ដឹងបាប) ។ ជ័យជំនះរបស់ហ៊ូសែន៍ ទោះបីមានគ្នាតិចក៏ដោយ ធ្វើឲ្យខ្ញុំស្ងប់ស្ងែង ។"

មានរឿងពិតច្រើនដែរសរសេរដោយលោកអ្នកប្រាជ្ញស៊ូអាស់ល្បីៗ ដូចជា ស្ទៃខ៊ុ អាប់បាស់ អាល់-គុម្មី និង ស្ទៃខ៊ុ អាល់-មូហ្វីដុ ជាដើម ។

ក្រាំងប្រវត្តិសាស្ត្រទាំងនេះ - ស៊ុន្នីនិងស៊ីអាស់ មុស្លីមនិងមិនមែនមុស្លីម - បញ្ជាក់យ៉ាងច្បាស់លាស់ថាសោកនាដកម្មការបាឡាអ៊ំបានកើតឡើងក្នុង



បញ្ជូនប្អូនជីដូនមួយរបស់ព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ឈ្មោះ មុស្លីម អ៊ីបនូ អាគ្វីល ទៅកាន់ស្រុកគូហ្វាស់ដើម្បីស្ទង់ស្ថានការណ៍ក្នុងស្រុកនេះ ។ ប្រជារាស្ត្រស្រុកគូហ្វាស់បានស្មោះស្ម័គ្រគាំទ្រលោក មុនក្បត់លោកពេលទ័ពរបស់យ៉ាស៊ីដុមកដល់ ។

ពួកអ្នកស្រុកគូហ្វាស់ទៅចូលរួមជាមួយកងទ័ពរបស់ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មិនទាន់ ឬចេញទៅការពារព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ មិនទាន់ពីពួកសត្រូវរបស់ព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ នោះ ។ សម័យឥឡូវ ១៤ សតវត្សក្រោយមក អ្នកធ្វើអត្ថាធិប្បាយមុស្លីមនិងមិនមែនមុស្លីមខ្លះថ្លែងការណ៍ថាពួកស៊ីអាស់ធ្វើពិធីម៉ាក់តាំថ្ងៃអាស៊ូរ៉ព្រោះតែមាន "កំហុស" ដែលមកមិនទាន់ពេលនិងដែលបានក្បត់ហ៊ូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ អ៊ីម៉ាំរបស់ខ្លួន ។ តែតាមប្រវត្តិសាស្ត្រ សម្តីនេះមិនសមហេតុផលទេ វាជាសម្តីដែលត្រូវប្រឌិតឡើងដើម្បីព្យាយាមលើកកំហុសចេញពីបណ្តាបុគ្គលមានកំហុសមែនទែន ក្នុងការសម្លាប់ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ និងក្រុមគ្រួសារព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ នៅឯការបាឡាអ៊ំ ។

## ហេតុការណ៍ពិតក្នុងប្រវត្តិសាស្ត្រ

ស្រុកគូហ្វាស់ ផ្ទុយពីការដឹងដោយស្មាន ពុំមែនជា "ស្រុកស៊ីអាស់" ទេ ។ លោក ស៊ីបលី នុអ៊ំម៉ានី (شِبلی نُعمانی) អ្នកប្រាជ្ញនិងអ្នកនិពន្ធជីវប្រវត្តិនិកាយស៊ុនណាស់ មានប្រសាសន៍ថាគូហ្វាស់ជាស្រុកមួយនៅឯប្រទេសអ៊ីរ៉ាក់ត្រូវកសាងឡើងដោយ អ៊ុម៉ារ អ៊ីបនូ ខុត្តុប់ ក្នុងសម័យគាត់កាន់ខ៊ុលីហ្វាស់ ជាបន្ទាយមួយសម្រាប់កងទ័ពនិងបណ្តាបក្សពួករបស់គាត់ ។

ក្រោយមក ព្រះសន្តអ៊ីម៉ាំអាលី صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ បានទៅនៅស្រុកនេះសម័យព្រះអង្គ صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَامُ ជាស្តេចខ៊ុលិហ្វ ដើម្បីឃ្លាំមើលមូអាវីយ៉ាស់ អ៊ីបនូ អាប៊ូ ស៊ុហ្វយ៉ាន

បុគ្គលបះបោរប៉ប្លិចប៉ប្លូចនៅក្បែរប្រទេសស៊ីរី ។ ក្រោយពីព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام ចូលព្រះទិវង្គត លោក ត៉្បារី អ្នកប្រវត្តិសាស្ត្រនិកាយស៊ុន្នី មានប្រសាសន៍ថាពួកស្ហ៊ីអាស់ស្រុកគូហ្វាស់ ដែលបានមកកាន់ស្រុកនេះជាមួយ អាលី អ៊ីបនូ អាប៊ូ ត៉្លលិបصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام ត្រូវចាប់ខ្លួន ត្រូវធ្វើទណ្ឌកម្ម ត្រូវកាប់សម្លាប់ដោយស៊ីយ៉ាដ់ បុគ្គលតែងតាំងរបស់មូអាវីយ៉ាស់ (និងឪពុករបស់អ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ់ដែលជាអភិបាលស្រុកគូហ្វាស់សម័យសោកនាដកម្មការបាឡាអ៊្) ។

អាប់ឌុលឡោះហ៍ អ៊ីបនូ អាប់បាស់ សាវកជាទីគោរពរបស់ព្រះសាស្តាមូហាំម៉ាដ់صَلَّى اللهُ عَلَيْهِ وَآلِه បងប្អូនជីដូនមួយរបស់ព្រះអង្គصَلَّى اللهُ عَلَيْهِ وَآلِه បានប្រាប់ព្រះសន្តអ៊ីម៉ាំហ៊្សូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام ឲ្យដឹងជាមុនដែរ កាលព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام បានចាកចេញពីម៉ាឌីណាស់ ថាពួកអ្នកស្រុកគូហ្វាស់ជា "មនុស្សបោកប្រាស់" មិនអាចទុកចិត្តពួកគេនោះបានទេ ។

ម្យ៉ាងទៀត ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់មួយបញ្ជាក់ថាកងទ័ពរបស់យ៉ាស៊ីដ្ឋបានផ្តើមបង្កត់បាយ បន្ទាប់មកបានសម្លាប់ព្រះសន្តអ៊ីម៉ាំហ៊្សូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام ឯបណ្តាអ្នកតាមព្រះអង្គصَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام មកពីប្រទេសស៊ីរី មិនមែនមកពីស្រុកគូហ្វាស់ទេ ។ លោក ស្ហាស់ អាប់ឌុល-អាស៊ីស (شاه عبد العزيز) អ្នកប្រាជ្ញនិកាយស៊ុន្នី បានតំណាលរឿងនេះថា៖ "បណ្តាកងទ័ពស៊ីរី ក្រោមបញ្ជាយ៉ាស៊ីដ្ឋនិងក្រោមការព្យាយាមរបស់មេប្រឆាំងនិងមេហ្វីតណាស់ គឺអ៊ីបនូ ស៊ីយ៉ាដ់ បានកាប់សម្លាប់អ៊ីម៉ាំហ៊្សូសៃន៍صَلَوَاتُ اللهِ عَلَيْهِ وَالسَّلَام នៅការបាឡាអ៊្ ។"

រឿងរ៉ាវនៅការបាឡាអ៊្ត្រូវចារទុកក្នុងក្រាំងសំណេរ អាស់លុល-ស៊ុនណាស់ច្រើន ។ រឿងរ៉ាវនេះបង្ហាញឲ្យឃើញជាក់ច្បាស់ថាអ្នកណាខ្លះជាអ្នកមានកំហុស ឬពុំមានកំហុសក្នុងការកាប់សម្លាប់ព្រះសន្តអ៊ីម៉ាំ



ផ្ទាត់ ពីសតវត្សទី ៧ និងទី ៨ ឯសេចក្តីថ្លែងការណ៍អំពីវគ្គសំខាន់ៗទាំងនេះត្រូវគ្នា ។

លោក អាប៊ូ មិក្ហណាហ្វ (أبو مخنف) អ្នកប្រវត្តិសាស្ត្រស្រុកគូហ្វាស់ បានសរសេរសាត្រាដំបូងបង្អស់មានចំណងជើងថា "ម៉ាក់តាល់ អាល់-ហ៊្សូសៃន៍ (مَقْتَل اَلْحُسَيْن) ក្នុងឆ្នាំ ៧៨៨ គ្រិស្តសករាជ ពោលគឺ ក្នុងចន្លោះពេល ១០០ ឆ្នាំបន្ទាប់ព្រឹត្តិការណ៍ការបាឡាអ៊្ ច្រើនឆ្នាំមុនជីវប្រវត្តិមួយចំនួនដែលគេបានសរសេរអំពីព្រះសាស្តា និងព្រឹត្តិការណ៍សាសនាឯទៀត ។ ឧទាហរណ៍ គម្ពីរសាសនាគ្រិស្តត្រូវបានចងក្រងឡើងលើសពីមួយរយឆ្នាំក្រោយយេស៊ូ (អ៊ីសាعَلَيْهِ السَّلَام) បានចាកចោលលោកនេះ ។

ឧទាហរណ៍ ប្រៀបធៀបសាត្រាម៉ាក់តាល់របស់អាប៊ូ មិក្ហណាហ្វ - ដែលទៅជាប្រភពព័ត៌មាន (ឯកសារដើម) សម្រាប់ប្រវត្តិសាស្ត្រមុស្លីមក្រោយៗដូចជា ត៉្បារី (الطبري) និង បាឡាស៊ូរី (البلاذري) ជាដើម - ជាមួយ ស៉ហ៊ិះហ៍ ប៊ូខ៉ារី (صَحِيح اَلْبُخَارِيّ) ដែលត្រូវចងក្រងឡើងប្រមាណលើសពី ២០០ ឆ្នាំក្រោយព្រះសាស្តាមូហាំម៉ាដ់صَلَّى اللهُ عَلَيْهِ وَآلِه សោយព្រះទិវង្គត ។

## ឯកសារយោងដកស្រង់មកពីក្រាំងសំណេររបស់អាស់លុល-ស៊ុនណាស់

លោកអ្នកប្រវត្តិសាស្ត្រនិកាយស៊ុន្នី ដូចជា ត៉្បារី, បាឡាស៊ូរី ជាដើម បានចាត់ទុកវណ្ណកម្មរបស់លោកមិក្ហណាហ្វថាត្រឹមត្រូវពិតប្រាកដ ហើយបានចម្លងវណ្ណកម្មរបស់លោកមិក្ហណាហ្វបន្ថុលក្នុងវណ្ណកម្មរបស់ខ្លួន ។ ក្រាំងប្រវត្តិសាស្ត្ររបស់លោកត៉្បារី ក្បាលទី ១៩, ក្នុងវគ្គស្តីអំពីខ៉លីហ្វាស់របស់ យ៉ាស៊ីដ្ឋ អ៊ីបនូ មូអាវីយ៉ាស់, ធ្វើសេចក្តីរាយការណ៍លំអិតអំពីតួនាទីរបស់យ៉ាស៊ីដ្ឋក្នុងសោកនាដកម្មការបាឡាអ៊្ និងនៅក្នុងសមរភូមិ

ពុំឃើញមានការអត់អាហារណាមួយ ជាការអត់អាហារដើម្បីរំលឹកថ្ងៃព្រះសាស្តាមូសា عليه السلام បានចាកចេញពីប្រទេសអេស៊ីបត៍ទេ ។ ហ្វាឌីស្ទប៊ូខ៍រីថ្លែងអំពីការអត់អាហារមិនពិត ក្នុងបំណងចង់ធ្វើឲ្យអាស៊ូរ៉មានន័យខ្លឹមសារផ្សេង មិនទាក់ទងនឹងហ៊ូសែន៍ صلوات الله عليه والسلام ។

ចំណុចចុងក្រោយបង្អស់ដែលត្រូវចាប់អារម្មណ៍ត្រង់នេះគឺ ឧបមាថាប៊ូខ៍រីនិងបក្សពួកជាអ្នកត្រូវមួយពេលសិន ថាមានថ្ងៃកាន់សីលអត់អាហាររបស់ពួកយ៉ាហ៊ូឌីបើកឲ្យដឹងដោយព្រះសាស្តាមូសា عليه السلام មែន ដែលត្រូវគ្នានឹងថ្ងៃអាស៊ូរ៉ក្នុងខែមូហារ៉ម ។ ទោះជាដូច្នេះក៏ដោយ តើថ្ងៃកាន់សីលអត់អាហាររបស់ពួកយ៉ាហ៊ូឌីនោះ នឹងលុបលើឬជួសសារសំខាន់របស់ការលះលង់និងការបូជាព្រះជន្មរបស់ព្រះសន្តអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام នៅឯស្រុកការបាឡាអ៊ុំថ្ងៃអាស៊ូរ៉ដូច្នោះឬ ? អាចដូច្នេះបានដូចម្តេច ?

# តើស៊ីអាស់អាចជឿរឿងការបាឡាអ៊ុំបានដូចម្តេច ?

## ព្រឹត្តិការណ៍កន្លងមក

បុគ្គលខ្លះគិតថារឿងអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام និងសោកនាដកម្មការបាឡាអ៊ុំ ជាប្រជុំរឿងព្រេងនិងរឿងនិទាន ។ ផ្ទុយទៅវិញ ការពិតគឺមានព្រឹត្តិការណ៍តិចក្នុងប្រវត្តិសាស្ត្រអ៊ីស្លាមដែលមានឯកសារ និងមានការអត្ថាធិប្បាយដែលទុកចិត្តបានជាអំណះអំណាង ដូចព្រឹត្តិការណ៍ការបាឡាអ៊ុំក្នុងឆ្នាំ ៦៨០ គ្រិស្តសករាជនោះ ។

អ្នកប្រវត្តិសាស្ត្រមុស្លីមដែលទុកចិត្តបាន បានធ្វើសេចក្តីរាយការណ៍វគ្គសំខាន់ៗ ដោយមានបណ្តាញថ្លែងព័ត៌មានបន្តគួរឲ្យជឿបាននិងផ្ទៀង



ហ៊ូសែន៍ صلوات الله عليه والسلام ។ សម័យសព្វថ្ងៃនេះ បណ្តាមុស្លីមដែលអះអាងថាយ៉ាស៊ិដ្ឋអ៊ិបនូ មូអាវីយ៉ាស់ មិនមែនអ្នកទទួលខុសត្រូវរឿងនេះទេ បណ្តាបុគ្គលទាំងនោះដូចពួកណាស៊ី (nazi) ដែលបដិសេធថាហ៊ីត្លែរ (Hitler) មិនមែនអ្នកទទួលខុសត្រូវការកាប់សម្លាប់រង្គាល (Holocaust) ទេក្នុងរបបផ្តាច់ការអាល្លឺម៉ង់នោះ ។

# អាស៊ូរ៉ជាថ្ងៃកាន់សីលអត់អាហារ មិនមែនថ្ងៃកាន់មរណទុក្ខទេ ?

អ្នកអាស្ហលុល-ស៊ុនណាស្ហខ្លះ ដូចជាមានបំណងមើលថោកអាស៊ូរ៉វិស័យសាសនានិងវិស័យវិញ្ញាណឬចិត្ត ចង់បំបែរអារម្មណ៍សំណាក់មុស្លីមពីព្រឹត្តិការណ៍អាស៊ូរ៉ក្នុងប្រវត្តិសាស្ត្រ ។ ដូច្នេះពួកគេនោះដើរនិយាយឧទាហរណ៍ ថាថ្ងៃអាស៊ូរ៉ជាថ្ងៃកាន់សីលអត់អាហារ មិនមែនថ្ងៃកាន់មរណទុក្ខទេ ។

## ឯកសារយោងដកស្រង់ពីក្រាំងសំណេរអាស្ហលុល-ស៊ុនណាស្ហ

ហ្វាឌីស្ទ[ដែលមិនគួរឲ្យទុកចិត្តបាន]នៅក្នុងសៀវភៅស៊ុនីថ្លែងថា កាលព្រះសាស្តាមូហាំម៉ាដ្ ﷺ បានមកកាន់ម៉ាឌីណាស្ហឆ្នាំ ៦២២ គ្រិស្តសករាជ ព្រះអង្គ ﷺ ឃើញពួកយ៉ាហ៊ូឌីស្រុកនេះកាន់សីលអត់អាហារ ។ ព្រះអង្គ ﷺ បានសួរថាហេតុអ្វីពួកគេកាន់សីលអត់អាហារ គេបានប្រាប់ព្រះអង្គ ﷺ ថានេះជា "ថ្ងៃពរជ័យ" គឺថ្ងៃដែលព្រះសាស្តាមូសា عليه السلام បានចាកចេញពីប្រទេសអេស៊ីបត៍ ។ ព្រះសន្តសាស្តានៃព្រះសាសនាអ៊ីស្លាម ﷺ ក៏បានប្រាប់ពួកយ៉ាហ៊ូឌីថាយើងជា "បុគ្គលជំនិតរបស់មូសា عليه السلام ជាងអស់លោក" ហើយព្រះអង្គ ﷺ បានដាក់បញ្ហាលើមុស្លីមឲ្យកាន់សីលអត់អាហារថ្ងៃនោះដែរ - យោលតាមសាគ្រា ស្ហ៊ីហ៊ុះហ៊ ប៊ូខ៍រី ។

មានថ្លែងនៅក្នុងមុសណាដ្ជ៎របស់អ៊ីម៉ាំអាស្ម៉ាដ្ជ៎ អ៊ីបនូ ហ្វាន់បាល់ដែរថា ព្រះសាស្តាមូហ្ហាំម៉ាដ្ជ៎ صلى الله عليه وآله បានប្រាប់បណ្តាសាវកព្រះអង្គ صلى الله عليه وآله ថា៖ "ចូរអស់លោកកាន់សីលអត់ហារថ្ងៃអាស៊ូរ៉ តែចូរធ្វើខុសពីពួកយ៉ាហ៊ូឌីដោយអត់អាហារមួយថ្ងៃមុនថ្ងៃអាស៊ូរ៉ ហើយអត់អាហារមួយថ្ងៃក្រោយថ្ងៃអាស៊ូរ៉ ។"

ស៊ីអាស្ម៉ិនជឿទេថាហាឌីស្ទទាំងនេះជាហាឌីស្ទពិតប្រាកដ ឬគួរតាមទេ ពីព្រោះថា៖

- មានការសង្ស័យអំពីការពិតរបស់ហាឌីស្ទនេះ ។ អ្នកថ្លែងហាឌីស្ទនេះបីនាក់គឺ មូអាវីយ៉ាស្ហ៎ អ៊ីបនូ ស៊ូហ្វាយ៉ានដែលបានទៅជាមុស្លីមមុនព្រះសាស្តាមូហ្ហាំម៉ាដ្ជ៎ صلى الله عليه وآله សោយព្រះទុវង្គតបន្តិច គាត់អវត្តមានកាលព្រះអង្គ صلى الله عليه وآله មកដល់ម៉ាឌីណាស្ហ៎ (ការពិតគឺគាត់ជាអ្នកប្រឆាំងកូនៗរបស់អាលី អ៊ីបនូ អាប៊ូ ត៉ូលិប صلوات الله عليه والسلام); អាប៊ូ ហ៊ូរ៉យ់រ៉ោះត៎ ដែលបានទៅជាមុស្លីមឆ្នាំ ៦២៩ គ្រិស្តសករាជ គាត់ក៏អវត្តមានដែរកាលព្រះសាស្តាមូហ្ហាំម៉ាដ្ជ៎ صلى الله عليه وآله បានមកដល់ម៉ាឌីណាស្ហ៎ គាត់បានថ្លែងថាគាត់បានឃើញពួកយ៉ាហ៊ូឌីកាន់សីលអត់អាហារថ្ងៃអាស៊ូរ៉ (ការធ្វើសាក្សីរបស់គាត់ដូចយើងបានអធិប្បាយរួចមកហើយនោះ មិនអាចយកជាការបានទេ); អាប់ឌុលឡោះហ្ហ៍ អ៊ីបនូ អាប់បាស់ លោកនៅក្មេងក្នុងឆ្នាំ ៦២២ គ្រិស្តសករាជ ដូច្នេះអំណះអំណាងរបស់លោកអំពីរឿងនេះក៏ពុំអាចយកជាការបានដែរ ។

- អាស៊ូរ៉មានអត្ថន័យលើសពីមួយ ។ អត្ថន័យដើមរបស់អាស៊ូរ៉ មុនសម័យការបាឡាអ៊ុំ គឺ "ទីដប់" គឺទីដប់របស់គ្រប់ៗខែ ។ ពីព្រោះគេប្រមាណថាព្រះសាស្តាមូហ្ហាំម៉ាដ្ជ៎ صلى الله عليه وآله មកដល់ម៉ាឌីណាស្ហ៎ "ថ្ងៃទីដប់" មិនបានសេចក្តីថាព្រះអង្គ صلى الله عليه وآله មកដល់ថ្ងៃទីដប់ខែមូហារ៉មទេ ។



- ប្រក្រតិទិនរបស់ពួកយ៉ាហ៊ូឌី គ្រាន់តែជាប្រក្រតិទិនចន្ទគតិតែពាក់កណ្តាលទេ ដូច្នេះវាមិនស្របយ៉ាងពេញលេញនឹងប្រក្រតិទិនចន្ទគតិរបស់អ៊ីស្លាមជាអចិន្ត្រៃយ៍ទេ ។ អាស្រ័យហេតុនេះ បើថ្ងៃបុណ្យនេះមាននៅក្នុងប្រក្រតិទិនយ៉ាហ៊ូឌីមែន វាមិនត្រូវនឹងថ្ងៃទីដប់ខែមូហារ៉មទេ ពីឆ្នាំមួយទៅឆ្នាំមួយ ។

## សីលអត់អាហាររបស់ពួកយ៉ាហ៊ូឌី

ដំបូងបង្អស់ សំណួរសំខាន់បំផុតដែលស៊ីអាស្ហ៎សួរបកទៅវិញគឺ យើងដឹងដូចម្តេចថាពួកយ៉ាហ៊ូឌីមានការកាន់សីលអត់អាហារនេះ ? បណ្តាភ័ស្តុតាងបញ្ជាក់ឲ្យដឹងថាពុំមានការកាន់សីលអត់អាហារបែបនេះ ដូចប៊ូខ៉ារីបានរៀបរាប់នោះទេ ជាសញ្ញាសំគាល់នៃការចាកចេញរបស់ព្រះសាស្តាមូសា عليه السلام ពីប្រទេសអេស៊ីបត៍ ។

ការពិតគឺ ពួកយ៉ាហ៊ូឌីកាន់សីលអត់អាហារក្នុងថ្ងៃចំនួនប្រាំពីរក្នុងមួយឆ្នាំគឺ៖

- អត់អាហារថ្ងៃ យុម គីពួរ
- អត់អាហារថ្ងៃ ទីស្ហា បាវ
- អត់អាហារថ្ងៃ គេដាលីយ៉ា
- អត់អាហារថ្ងៃទីដប់ខែទេវេត
- អត់អាហារថ្ងៃទី ១៧ ខែតាំមុស្ស
- អត់អាហារអេសថែរ (Esther)
- អត់អាហារកូនដំបូង (កូនបងគេ)